

ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព

# គោលការណ៍ និងសេចក្តីណែនាំ ស្តីពីសុចរិតភាព (២០១៥)

ធនាគារអភិវឌ្ឍន៍អាស៊ី

ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព

# គោលការណ៍ និងសេចក្ដីណែនាំ ស្ដីពីសុចរិតភាព (២០១៥)

ធនាគារអភិវឌ្ឍន៍អាស៊ី

ADB

# មាតិកា

គោលការណ៍ និងសេចក្តីណែនាំស្តីពីសុចរិតភាព (ខែ មករា ២០១៥)*

**I. គោលការណ៍ និងសេចក្តីណែនាំសម្រាប់ការស៊ើបអង្កេត របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ 1**
បុព្វកថា 1
គោលការណ៍ទូទៅ 3
និយមន័យ 16
សិទ្ធិ និងកាតព្វកិច្ច 17
សេចក្តីណែនាំអំពីនីតិវិធី 25
លទ្ធផលនៃការស៊ើបអង្កេត 30
ការផ្តល់ព័ត៌មានទៅអាជ្ញាធរជាតិ 32
ការពិនិត្យមើលឡើងវិញ និងការធ្វើវិសោធនកម្ម 32
ការបោះពុម្ពផ្សាយ 32

**II. ទោសទណ្ឌ 33**
មូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវ 33
ការជូនដំណឹងដល់ភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេត 35
សកម្មភាពកែតម្រូវ 39
រយៈពេលនៃការហាមឃាត់ 51
ការប្តឹងឧទ្ធរណ៍ 57
ការទទួលស្គាល់ឡើងវិញ 60
ការបង្ហាញព័ត៌មានជាសាធារណៈ 64
ការហាមឃាត់ឱ្យគ្នាទៅវិញទៅមក 65

* គោលការណ៍ និងសេចក្តីណែនាំនេះ មានអធិកភាពទៅលើគោលការណ៍ និងសេចក្តីណែនាំស្តីពីសុចរិតភាព ដែលចេញក្នុងឆ្នាំ២០០៦ និងកែសម្រួលឡើងវិញ ក្នុងឆ្នាំ២០១២

Creative Commons Creative Commons
Attribution-NonCommercial-NoDerivs 3.0
IGO license (CC BY-NC-ND 3.0 IGO)

© 2015 Asian Development Bank
6 ADB Avenue, Mandaluyong City, 1550 Metro Manila, Philippines
Tel +63 2 632 4444; Fax +63 2 636 2444
www.adb.org; openaccess.adb.org
OARsupport@adb.org; publications@adb.org

Some rights reserved. Published in 2015.
Printed in the Philippines.

ISBN 978-92-9254-961-9 (Print), 978-92-9254-962-6 (e-ISBN)
Publication Stock No. TIM157129

ទស្សនៈដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយវាមិនឆ្លុះបញ្ចាំងឱ្យទស្សនៈ និងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ គណៈអភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ រដ្ឋាភិបាលដែលពួកគេតំណាងឱ្យឡើយ។ ការនិយាយសំដៅយោងចំពោះដែនដី ឬ តំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ឬ តាមរយៈការប្រើប្រាស់ពាក្យថា “ប្រទេស” នៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី ពុំមានបំណងធ្វើការវិនិច្ឆ័យទៅលើស្ថានភាពផ្លូវច្បាប់ ឬ ស្ថានភាពដទៃទៀតរបស់ដែនដី ឬ តំបន់ណាមួយឡើយ។

ឯកសារនេះអាចរកបាននៅ Creative Commons Attribution-Non Commercial-No Derivs 3.0 IGO license (CC BY-NC-ND 3.0 IGO) http://creativecommons.org/licenses/by-nc-nd/3.0/igo/។ តាមរយៈការប្រើប្រាស់ឯកសារនេះ អ្នកបានយល់ព្រមអនុវត្តតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណខាងលើ ព្រមទាំងលក្ខខណ្ឌនៃការប្រើប្រាស់កន្លែងតម្កល់ឯកសារបើកចំហររបស់ធនាគារអភិវឌ្ឍន៍អាស៊ី: openaccess.adb.org/termsofuse។

អាជ្ញាប័ណ្ណ CC មិនអាចយកមកអនុវត្តបានចំពោះឯកសារដែលគ្មានការរក្សាសិទ្ធិ ដែលមិនមានជាឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងឯកសារនេះបានឡើយ។

សម្គាល់៖ នៅក្នុងឯកសារបោះពុម្ពនេះ “$” សំដៅចំពោះដុល្លាសហរដ្ឋអាមេរិក។

បោះពុម្ពលើក្រដាសកែច្នៃឡើងវិញ

“ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានខិតខំប្រឹងប្រែងដើម្បីផ្ទៀងផ្ទាត់ទៅលើភាពជាក់លាក់នៃការបកប្រែនេះ។ ភាសាអង់គ្លេសគឺជាភាសាការងាររបស់ ADB ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសគឺជាឯកសារដែលត្រឹមត្រូវ និងផ្លូវការតែមួយគត់របស់ខ្លួន។ សេចក្តីដកស្រង់ណាមួយចេញពីឯកសារនេះ ត្រូវតែយោងទៅលើឯកសារច្បាប់ដើមក្នុងភាសាអង់គ្លេស”។

# I. គោលការណ៍ និងសេចក្ដីណែនាំសម្រាប់ការស៊ើបអង្កេតរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ[1]

## បុព្វកថា

បណ្ដាស្ថាប័នទាំងនេះ បានអនុម័តរួមគ្នានូវគោលការណ៍ និងសេចក្ដីណែនាំរួមសម្រាប់ការស៊ើបអង្កេតដែលបានរៀបចំឡើងដោយអង្គភាពស៊ើបអង្កេតរបស់ស្ថាប័នរៀងៗខ្លួនដូចខាងក្រោម ៖

- ក្រុមធនាគារអភិវឌ្ឍន៍អាហ្វ្រិក
- ធនាគារអភិវឌ្ឍន៍អាស៊ី
- ធនាគារអឺរ៉ុបសម្រាប់ការស្ដារ និងអភិវឌ្ឍន៍
- ក្រុមធនាគារអភិវឌ្ឍន៍អន្តរអាមេរិកកាំង
- ក្រុមធនាគារពិភពលោក

1 គោលការណ៍ និងសេចក្ដីណែនាំរបស់ស្ថាប័នហិរញ្ញវត្ថុស្ដីពីការស៊ើបអង្កេត ដែលត្រូវបានអនុម័តដោយស្ថាប័នជាច្រើន ត្រូវបានដាក់បញ្ចូលជាផ្នែកទីមួយនៃគោលការណ៍ និងសេចក្ដីណែនាំអំពីសុចរិតភាពនេះ ដោយកថាខ័ណ្ឌដែលពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ត្រូវបានដាក់បញ្ចូល។

គោលការណ៍ និងសេចក្តីណែនាំទាំងនេះ មានគោលដៅយកមកប្រើប្រាស់ជាការណែនាំដើម្បីធ្វើការស៊ើបអង្កេតរួមជាមួយនឹងគោលនយោបាយច្បាប់ បទប្បញ្ញត្តិ បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិដែលអាចអនុវត្តបាននៅក្នុងអង្គការ[2] ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

គោលការណ៍និងសេចក្តីណែនាំទាំងនេះ នឹងត្រូវអនុវត្តចំពោះការិយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព (OAI) បុគ្គលិករបស់ការិយាល័យនេះ និងភាគីទាំងឡាយដែល OAI អនុញ្ញាត ឬ ដែលប្រធានធនាគារតែងតាំងឱ្យធ្វើការស៊ើបអង្កេតជំនួសឱ្យ OAI និងគ្រប់បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីទាំងអស់ ក៏ដូចជាទីប្រឹក្សា និងអ្នកទទួលបានកិច្ចសន្យា ដែលធនាគារអភិវឌ្ឍន៍អាស៊ីជួល និង ភាគីទី ៣ ដទៃទៀត ដែលចូលរួមនៅក្នុងសកម្មភាពពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី[3]ក្នុងការគោរពទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ[4]។

---

2 គោលការណ៍ណែនាំនេះមិនមានគោលបំណងប្រគល់ ដាក់ចេញ ឬផ្តល់ករណីយកិច្ច កាតព្វកិច្ច ឬសិទ្ធិដាក់ពាក្យបណ្តឹងនៅក្នុងច្បាប់តុលាការ ឬ ក្នុងនីតិវិធីរដ្ឋបាលចំពោះ អង្គការដែលកំពុងធ្វើការស៊ើបអង្កេតនោះទេ ។ គ្មានចំណុចណាមួយនៅក្នុងគោលការណ៍ណែនាំនេះ ត្រូវបានបកស្រាយ ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច របស់អង្គការនីមួយៗតាមច្បាប់ គោលនយោបាយ និងនីតិវិធីនានារបស់ខ្លួន ហើយក៏គ្មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិត្រូវផ្តល់ឱ្យអង្គការនីមួយៗ ដោយសន្ធិសញ្ញាអន្តរជាតិ និងច្បាប់របស់ប្រទេសជាសមាជិកឡើយ ។

3 "សកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានកំណត់និយមន័យនៅក្នុងកថាខណ្ឌ ១.គ *infra*

4 ឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R-89-98 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយដែលត្រូវបានអនុម័តនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៨ ដូចដែលបានបញ្ជាក់នៅក្នុងឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R185-04 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ ៖ សំណើបញ្ជាក់និងការផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងសេចក្តីណែនាំអំពីការពិគ្រោះយោបល់ និងលទ្ធកម្មដែលទទួលបានការអនុម័តនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R179-06 គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ ៖ និយមន័យរួមស្តីពីការអនុវត្តអំពើពុករលួយ និងការកេងបន្លំដែលត្រូវបានអនុម័តកាលថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៦។

ចំពោះគោលបំណងនៃឯកសារនេះ ការប្រើប្រាស់ពាក្យថា "អង្គការ" សំដៅដល់គ្រប់ស្ថាប័នទាំងអស់ដែលជាផ្នែកឬដែលទាក់ទងនឹងស្ថាប័នដែលបានលើកឡើងខាងលើ ។ ចាប់ពីពេលនេះតទៅ អង្គភាពស៊ើបអង្កេតរបស់អង្គការនីមួយៗ ហៅថា "**ការិយាល័យស៊ើបអង្កេត**" ។

## គោលការណ៍ទូទៅ

១. អង្គការនីមួយៗ ត្រូវមានការិយាល័យស៊ើបអង្កេតមួយដែលទទួលបន្ទុកធ្វើការស៊ើបអង្កេត ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព គឺជាការិយាល័យទំនាក់ទំនងបឋម និង ជាការិយាល័យដែលធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តល្មើសនានា ដែលពាក់ព័ន្ធនឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ឬ បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

១.ខ. "ការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព" សំដៅលើសកម្មភាពទាំងឡាយណា ដែលបំពានលើគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដូចជា អំពើពុករលួយ ការគៃបន្លំ ការបង្ខិតបង្ខំ ឬការសមគំនិតគ្នា ការរំលោភបំពាន ទំនាស់ផលប្រយោជន៍[5] និងការរារាំងបន្ទុចបង្អាក់ ដូចដែលបានកំណត់នៅក្នុងឯកសារនេះ។

តទៅទំព័របន្ទាប់

5 ទំនាស់ផលប្រយោជន៍ (COI) នៅក្នុងរាល់គ្រប់ករណីទាំងអស់ចំពោះបញ្ហានេះ អាចមិនមែនជាការបំពានសុចរិតភាព។

ប្រអប់បន្តទៀត

១.គ. “សកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី” រួមមានសកម្មភាពដែលទទួលហិរញ្ញប្បទាន ចាត់ចែង ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ឬសកម្មភាពទាំងឡាយណាដែលមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ឬ អាចមានផលប៉ះពាល់ ឬ ពាក់ព័ន្ធជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី។

១.ឃ. “កិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក” សំដៅលើកិច្ចព្រមព្រៀងពង្រឹងសេចក្ដីសម្រេចចិត្តហាមឃាត់ឱ្យគ្នាទៅវិញទៅមករវាង ADB និងស្ថាប័នចូលរួមដទៃទៀត ដែលផ្ដល់លទ្ធភាពឱ្យស្ថាប័នចូលរួមក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ពង្រឹងការអនុវត្តទណ្ឌកម្មប្រឆាំងនឹងអំពើពុករលួយ ការគៃបន្លំ អំពើបង្ខិតបង្ខំ និងការសមគំនិតគ្នា ដែលរកឃើញ និង ផ្សព្វផ្សាយជាសាធារណៈ ដោយស្ថាប័នចូលរួមដទៃទៀត។

១.ង. “ស្ថាប័នចូលរួម” សំដៅលើហត្ថលេខីនៃកិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក និងស្ថាប័នផ្សេងទៀត ដែលក្លាយជាភាគីនៃកិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក នៅពេលក្រោយទៀត។[6]

២. គោលបំណងនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេត គឺដើម្បីត្រួតពិនិត្យ និង បញ្ជាក់នូវសច្ចភាពនៃការចោទប្រកាន់ពីអំពើពុករលួយ ឬ

6 ហត្ថលេខីដំបូងៗ រួមមាន ក្រុមធនាគារអភិវឌ្ឍន៍អាហ្វ្រិក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអឺរ៉ុបសម្រាប់ការស្ដារឡើងវិញ និងការអភិវឌ្ឍ ក្រុមធនាគារអភិវឌ្ឍន៍អន្តរអាមេរិក និងក្រុមធនាគារពិភពលោក។ បើតាមកិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក ស្ថាប័នហិរញ្ញវត្ថុដទៃទៀតអាចចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ បន្ទាប់ពីមានការយល់ព្រមពីស្ថាប័នចូលរួមទាំងអស់។

អំពើគៃបន្លំ ដូចដែលបានកំណត់ដោយស្ថាប័ននីមួយៗ រួមទាំងការពាក់ព័ន្ធ តែមិនកំណត់ចំពោះគម្រោងដែលផ្ដល់ហិរញ្ញប្បទានដោយអង្គការ និងការចោទប្រកាន់ពីបទប្រព្រឹត្តខុសឆ្គងទៅលើបញ្ហាណាមួយរបស់បុគ្គលិកក្នុងអង្គការឡើយ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

២.ក. ការប្រព្រឹត្តល្មើសនឹងសុចរិតភាព ដែលការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព អាចធ្វើការស៊ើបអង្កេត រួមមាន ៖

i. ការប្រព្រឹត្តអំពើពុករលួយ ដែលជាការផ្ដល់ជូន ការឱ្យ ការទទួល ឬ ការសុំដោយផ្ទាល់ ឬ ដោយប្រយោលនូវនូវអ្វីម៉្យាង ដែលមានតម្លៃ ក្នុងគោលដៅប្រើឥទ្ធិពលមិនត្រឹមត្រូវដល់សកម្មភាពរបស់ភាគីម្ខាងទៀត។

ii. ការប្រព្រឹត្តអំពើគៃបន្លំ ដែលជាការធ្វើសកម្មភាពអ្វីមួយ ឬការខកខានមិនបានធ្វើសកម្មភាពអ្វីមួយ ដូចជា ការភូតកុហកបំភ្លៃខុសពីការពិតជាក់ស្ដែង ដែលនាំឱ្យមានការយល់ខុស ទោះដោយចេតនាក្ដី ឬ ដោយធ្វេសប្រហែសក្ដី ឬការប៉ុនប៉ងធ្វើឱ្យភាគីម្ខាងទៀតមានការយល់ខុស ដើម្បីទទួលបានប្រាក់កាស ឬ ផលប្រយោជន៍ផ្សេងទៀត ឬ ដើម្បីគេចចេញពីកាតព្វកិច្ចណាមួយ។

iii. ការប្រព្រឹត្តអំពើបង្ខិតបង្ខំ ដែលជាការធ្វើឱ្យទន់ខ្សោយ ឬ ការបង្កមហន្តរាយ ឬការការគំរាមកំហែងធ្វើឱ្យទន់ខ្សោយ ឬ មហន្តរាយដោយផ្ទាល់ក្ដី ឬ ដោយប្រយោលក្ដីដល់ភាគីណាមួយ ឬ ទ្រព្យ

តទៅទំព័របន្ទាប់

សម្បត្តិរបស់គូភាគី ក្នុងការប្រើឥទ្ធិពលមិនត្រឹមត្រូវទៅលើសកម្មភាពរបស់ភាគីម្ខាងទៀត ។

iv. ការប្រព្រឹត្តអំពើឃុបឃិត ដែលជាការរៀបចំផែនការរវាងភាគីពីរ ឬ ច្រើន ដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងមិនត្រឹមត្រូវ រួមទាំងការប្រើឥទ្ធិពលមិនត្រឹមត្រូវទៅលើសកម្មភាពរបស់ភាគីម្ខាងទៀត។[7]

v. ការរំលោភបំពាន ដែលជាការលួច ខ្ជះខ្ជាយ ឬ ការប្រើប្រាស់មិនសមស្របនូវទ្រព្យសម្បត្តិពាក់ព័ន្ធនឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ទោះប្រព្រឹត្តដោយចេតនា ឬ ដោយអចេតនាក្ដី។

vi. ទំនាស់ផលប្រយោជន៍ ដែលជាស្ថានភាពណាមួយ ដែលក្នុងនោះភាគីមួយមានផលប្រយោជន៍ ដែលធ្វើឱ្យជះឥទ្ធិពលមិនល្អដល់ការបំពេញការងារកាតព្វកិច្ច ឬ ការទទួលខុសត្រូវផ្លូវការ កាតព្វកិច្ចនៃកិច្ចសន្យាឬការគោរពតាមច្បាប់និងបទបញ្ញានានាជាធរមាន។

vii. ការរារាំងបន្ទុចបង្អាក់ ដូចជា (ក) ការមានចេតនាបំផ្លាញ ក្លែងបន្លំ ផ្លាស់ប្តូរ ឬ ការលាក់បាំងភស្តុតាងដែលមានសារៈសំខាន់ ចំពោះការស៊ើបអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ខ) ការផ្ដល់សេចក្ដីថ្លែងក្លែងក្លាយដល់អ្នកស៊ើបអង្កេត ដើម្បីធ្វើឱ្យខូចដល់ការស៊ើបអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (គ) ការខកខានមិនបំពេញ

តទៅទំព័របន្ទាប់

7 និយមន័យនៃអំពើពុករលួយ ការកែបន្លំ ការបង្ខិតបង្ខំ និងការឃុបឃិត ត្រូវបានធ្វើសុខដុមនីយកម្មឱ្យស្របទៅតាមនិយមន័យរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត និងត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមឯកសាររបស់ក្រុមប្រឹក្សាភិបាលលេខ R179-06។

ប្រអប់បន្តទៀត

ទៅតាមការស្នើសុំឱ្យមានការផ្តល់ព័ត៌មាន ឯកសារ ឬ កំណត់ត្រានានា ដែលពាក់ព័ន្ធជាមួយនឹងការស៊ើបអង្កេតរបស់ OAI (ឃ) ការគម្រាមកំហែង ការបៀតបៀន ឬ ការសម្លុតភាគីណាមួយ ដើម្បីកុំឱ្យភាគីនោះបង្ហាញពីការដឹងឮ របស់ខ្លួនអំពីបញ្ហាដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត ឬមិនឱ្យមានការបន្តការស៊ើបអង្កេត ឬ (ង) រារាំងដល់សិទ្ធិធ្វើសវនកម្ម ឬ អធិការកិច្ច ទទួលព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចបញ្ជាក់នៅក្នុងកិច្ចសន្យា។

viii. ការបំពានលើទោសទណ្ឌដែលដាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ី។

ix. ការសងសឹកចំពោះអ្នកផ្តល់ព័ត៌មាន ឬ សាក្សី ដែលជាសកម្មភាពបង្កគ្រោះថ្នាក់ ដោយផ្ទាល់ ឬ ដោយប្រយោល ត្រូវបានផ្តល់ជាអនុសាសន៍ត្រូវបានគំរាមកំហែងឬអនុវត្តចំពោះអ្នកផ្តល់ព័ត៌មាន ឬ សាក្សី ឬអ្នកដែលមានទំនាក់ទំនងជាមួយអ្នកផ្តល់ព័ត៌មាន ឬ សាក្សី ក្នុងលក្ខណៈដែលអាចធ្វើឱ្យប៉ះពាល់ដល់ពាក្យបណ្តឹង ដោយសារតែអ្នកផ្តល់ព័ត៌មាន ឬសាក្សីនោះ រាយការណ៍ ឬសហការនៅក្នុងការស៊ើបអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលការប្រព្រឹត្តបែបនេះ ត្រូវមានការស៊ើបអង្កេត ទៅតាមបញ្ជារដ្ឋបាល (AO) លេខ ២.១០។[8]

x. ការប្រព្រឹត្តល្មើសដទៃទៀត ទៅនឹងគោលនយោបាយប្រឆាំងអំពើពុករលួយ ដូចជាការខកខានមិនអនុលោមទៅតាមស្តង់ដាក្រមសីលធម៌កម្រិតខ្ពស់បំផុតជាដើម។

តទៅទំព័របន្ទាប់

8 ការការពារអ្នកផ្តល់ព័ត៌មាន និងសាក្សី។

ប្រអប់បន្តទៀត

២.ខ. ការស៊ើបអង្កេត អាចដាក់បញ្ចូលការប៉ុនប៉ងប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព។

២.គ. ការចោទប្រកាន់ពីការប្រព្រឹត្តិមិនត្រឹមត្រូវ របស់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិល្មើសទៅនឹងសុចរិតភាព ឬការសងសឹកចំពោះអ្នកផ្តល់ព័ត៌មាន ឬសាក្សីនានា នឹងត្រូវស៊ើបអង្កេតទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ ដូចនៅក្នុងឧបសម្ព័ន្ធទី ២ នៃបញ្ញារដ្ឋបាលលេខ ២.០៧[9] និងបញ្ញារដ្ឋបាលលេខ ២.១០។

២.ឃ ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព អាចស៊ើបអង្កេតអំពីការប្រព្រឹត្តិមិនត្រឹមត្រូវផ្សេងទៀត ទៅតាមបទបញ្ញារដ្ឋបាលលេខ ២.០៤ ទៅតាមការស្នើសុំរបស់ប្រធានធនាគារ ឬអគ្គនាយក នាយកដ្ឋានថវិកា បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង។

៣. ការិយាល័យស៊ើបអង្កេត ត្រូវរក្សាតម្លាភាព អព្យាក្រឹតភាព និងភាពយុត្តិធម៌ក្នុងដំណើរការស៊ើបអង្កេតទាំងមូល និងធ្វើសកម្មភាពប្រកបដោយសមត្ថភាព និងសុចរិតភាពបំផុត ។ ជាពិសេស ការិយាល័យស៊ើបអង្កេតត្រូវប្រតិបត្តិការងាររបស់ខ្លួនដោយឯករាជ្យមិនជាប់ទាក់ទិននឹងអ្នកទទួលខុសត្រូវ ឬអ្នកពាក់ព័ន្ធនៅក្នុងសកម្មភាពប្រតិបត្តិ ព្រមទាំងមិនទាក់ទិននឹងបុគ្គលិកដែលជាគោលដៅនៃការស៊ើបអង្កេត និងមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលមិនសមស្រប និងការភ័យខ្លាចចំពោះការសងសឹក ។

9 វិធានការ និងនីតិវិធីដាក់វិន័យ។

៤. បុគ្គលិកនៃការិយាល័យស៊ើបអង្កេតត្រូវរាយការណ៍ជូនអ្នកគ្រប់គ្រងឱ្យបានទាន់ពេលនូវទំនាស់ផលប្រយោជន៍សំខាន់ៗ ឬជាក់ស្ដែងណាមួយដែលគាត់មានជាប់ពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតដែលខ្លួនកំពុងចូលរួម ហើយអ្នកគ្រប់គ្រងត្រូវចាត់វិធានការសមស្របដើម្បីដោះស្រាយទំនាស់នោះ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៤.ក. ការបង្ហាញពីទំនាស់ផលប្រយោជន៍ ត្រូវធ្វើឡើងទៅកាន់ប្រធានការិយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព ឬតំណាងរបស់គាត់ភ្លាមៗបន្ទាប់ពីការរកឃើញ និងមុនពេលដែលមានការស៊ើបអង្កេតអ្វីមួយ។ ទំនាស់ផលប្រយោជន៍ ដែលពាក់ព័ន្ធនឹងប្រធានការិយាល័យប្រឆាំងអំពើពុករលួយ និង សុចរិតភាព ត្រូវបង្ហាញទៅកាន់ប្រធានធនាគារ។ សកម្មភាពទាំងឡាយណា ដើម្បីគ្រប់គ្រងទំនាស់ផលប្រយោជន៍ ត្រូវមានការកត់ត្រា ជាលាយលក្ខណ៍អក្សរ។ សកម្មភាពដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍ អាចរួមមាន ប៉ុន្តែមិនកម្រិតត្រឹមការដកចេញពីការស៊ើបអង្កេត និងការកំហិតលើការទទួលបានឯកសារ និងព័ត៌មានអំពីករណី។

៥. ត្រូវអនុវត្តនីតិវិធីសមស្រប ដើម្បីស៊ើបអង្កេតទៅលើការចោទប្រកាន់ពីអំពើមិនគប្បីចំពោះបុគ្គលិកនៃការិយាល័យស៊ើបអង្កេត ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៥.ក. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹតល្មើសទៅនឹងសុចរិតភាព ឬ ការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលិក

តទៅទំព័របន្ទាប់

ប្រអប់បន្តទៀត

គ្រប់គ្រង នៅក្នុងការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ឬ នាយកដ្ឋានថវិកា បុគ្គលិក និងគ្រប់គ្រងប្រព័ន្ធ (BPMSD) អាចបញ្ជូនទៅកាន់អនុប្រធានធនាគារ (ទទួលបន្ទុកផ្នែកគ្រប់គ្រងរដ្ឋបាល និង ក្រុមហ៊ុន) ស្របទៅតាមបញ្ញារដ្ឋបាល AO 2.10 ខចែងលេខ ៤.៣។

៥.ខ. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹតល្មើសទៅនឹងសុចរិតភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់អនុប្រធានធនាគារណាម្នាក់ អាចបញ្ជូនទៅកាន់ប្រធានធនាគារ ស្របទៅតាមបញ្ញារដ្ឋបាល AO 2.10 ខចែងលេខ ៤.៤។

៥.គ. របាយការណ៍ពីការចោទប្រកាន់អំពីករណីសង្ស័យថាមានការប្រព្រឹតល្មើសទៅនឹងសុចរិតភាព ដោយបុគ្គលិកដទៃទៀតរបស់ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ទីប្រឹក្សា ឬ អ្នកទទួលបានកិច្ចសន្យានានា អាចបញ្ជូនដោយផ្ទាល់ទៅកាន់ប្រធាន ឬ នាយកការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព។

៦. អង្គការនីមួយៗ ត្រូវបោះពុម្ពផ្សាយនូវអាណត្តិនិង/ឬរយៈពេលកំណត់នៃការិយាល័យស៊ើបអង្កេតរបស់ខ្លួន ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំដែលពន្លេចឱ្យឃើញនូវសុចរិតភាព និងសកម្មភាពប្រឆាំងការគេបន្លំ និងអំពើពុករលួយនៃការិយាល័យស៊ើបអង្កេតរបស់ខ្លួន ដោយអនុលោមទៅតាមគោលនយោបាយបើកចំហរព័ត៌មាន ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៦.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI), បុគ្គលិករបស់ការិយាល័យនេះ, ភាគីនានា ដែល OAI អនុញ្ញាត ឬ បុគ្គលណាម្នាក់ ដែលប្រធានធនាគារតែងតាំងឱ្យធ្វើការស៊ើបអង្កេតជំនួសឱ្យ OAI ត្រូវធ្វើការវាយតម្លៃលើការចោទប្រកាន់នានា និងធ្វើការស៊ើបអង្កេតទៅតាមគោលការណ៍ និងសេចក្តីណែនាំទាំងនេះ និងត្រូវផ្តល់ជាអនុសាសន៍អំពីវិធានការរដ្ឋបាល ដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ីអនុវត្ត សំដៅដោះស្រាយបញ្ហាប្រឈមទាំងនេះ។

៦.ខ. ក្រោមលក្ខខណ្ឌយោងរបស់ខ្លួន ប្រធាន OAI ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធានធនាគារ។ គាត់ត្រូវរាយការណ៍ទៅកាន់ប្រធានធនាគារ និងទៅកាន់គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាលតាមរយៈប្រធានធនាគារ អំពីសកម្មភាព និងលទ្ធផលដែលសម្រេចបានដោយ OAI។ នៅក្នុងការបំពេញសកម្មភាពរបស់ OAI ប្រធាន OAI និងបុគ្គលិក OAI ដែលទទួលបានការអនុញ្ញាត អាចមានលទ្ធភាពដោយពេញលេញ និង ដោយមិនមានការកំហិត (អាចកាន់កាប់ ឬគ្រប់គ្រងជាបណ្តោះអាសន្ន) លើព័ត៌មាន និងឯកសារនានាដែលពាក់ព័ន្ធនឹងគ្រប់សកម្មភាព បុគ្គលិក និងអចលនទ្រព្យរូបវ័ន្តទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការទទួលខុសត្រូវសំខាន់ៗរបស់ OAI រួមមាន ៖

តទៅទំព័របន្ទាប់

- សហការជាមួយនឹងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។
- ធ្វើការពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធ ដើម្បីស្នើ និងពិនិត្យឡើងវិញ លើនីតិវិធីសមស្រប ក្រោមគោលនយោបាយប្រឆាំងអំពើពុករលួយនេះ សំដៅធានាយ៉ាងណាឱ្យបុគ្គលិក និងគម្រោង ដែលពាក់ព័ន្ធទាំងអស់ អនុលោមទៅតាមស្តង់ដាខ្ពស់បំផុត ដើម្បីរក្សាសុចរិតភាពប្រឆាំងនឹងអំពើពុករលួយ។
- បំពេញនាទីជាកន្លែងទំនាក់ទំនង សម្រាប់គ្រប់ការចោទប្រកាន់ទាំងអស់អំពីករណីបំពានសុចរិតភាព ដូចដែលបានកំណត់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ខ្លួន ក្នុងគ្រប់សកម្មភាពនានា ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី រាប់បញ្ចូលទាំងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។
- ធ្វើការស៊ើបអង្កេតដោយឯករាជ្យ និងដោយសត្យានុម័តលើករណីបំពានសុចរិតភាព ដោយអនុលោមទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែល OAI បានដឹង ឬបានរកឃើញ។
- ធ្វើការពិនិត្យឡើងវិញលើសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធជាមួយនឹងលទ្ធកម្ម ដើម្បីជួយបង្ការ និងរកឱ្យឃើញនូវករណីបំពានសុចរិតភាព។

តទៅទំព័របន្ទាប់

ប្រអប់បន្តទៀត

- ផ្តល់លទ្ធផលរកឃើញចេញពីការស៊ើបអង្កេត ដែលត្រូវធ្វើការតាមដានបន្ត ដូចដែលមានចែងនៅក្នុងគោលការណ៍ និងសេចក្តីណែនាំទាំងនេះ។

- នៅក្នុងការស៊ើបអង្កេត ត្រូវសម្របសម្រួលជាមួយគណៈគ្រប់គ្រង, ការិយាល័យអគ្គមេធាវី BPMSD និងនាយកដ្ឋាន/ការិយាល័យផ្សេងទៀត ទៅតាមការសមស្រប ហើយត្រូវអនុវត្តនីតិវិធី ដែលសមស្រប ដើម្បីកំណត់ថាតើមានករណីបំពានសុចរិតភាព នៅក្រោមគោលនយោបាយប្រឆាំងអំពើពុករលួយដែរឬអត់, ប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់, រៀបចំនីតិវិធី ដែលត្រូវអនុវត្តតាម ដើម្បីរកឱ្យឃើញនូវជនប្រព្រឹត្ត, កំណត់ពីវិសាលភាព បច្ចេកទេសដែលត្រូវបានប្រើប្រាស់ និងមូលហេតុដែលនាំឱ្យមានការបំពានសុចរិតភាព, កំណត់ថាតើចាំបាច់ត្រូវអនុវត្ត ឬពង្រឹងការត្រួតពិនិត្យ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដែរឬទេ និងរៀបចំយន្តការ ដើម្បីជួយបង្ហាញពីការកើតឡើងនូវការគៃបន្លំ ការប្រព្រឹត្តអំពើពុករលួយ ឬការរំលោភបំពានស្រដៀងៗគ្នា។

- ស៊ើបអង្កេតលើការចោទប្រកាន់ពីការប្រព្រឹត្តមិនត្រឹមត្រូវបំពានសុចរិតភាពរបស់បុគ្គលិក ដោយអនុលោមទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពនេះ និងទៅតាមឧបសម្ព័ន្ធទី ២ នៃបញ្ញារដ្ឋបាល ២.០៤។

- ស៊ើបអង្កេតលើការចោទប្រកាន់ពីការប្រព្រឹត្តមិនត្រឹមត្រូវ ដែលបញ្ជូនពីផ្នែកធនធានមនុស្ស ដោយអនុលោមទៅតាមបញ្ញារដ្ឋបាល ២.០៤។

- រៀបចំ និង ផ្ញើរបាយការណ៍ប្រចាំឆ្នាំ ទៅកាន់ប្រធានធនាគារ ដោយ

តទៅទំព័របន្ទាប់

ប្រអប់បន្តទៀត

សង្ខេបអំពីសកម្មភាពនានារបស់ខ្លួន។

- ដើម្បីពិគ្រោះយោបល់ និង សហការជាមួយធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត ស្ថាប័នហិរញ្ញវត្ថុ អន្តរជាតិ ឬ ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីផ្លោះប្តូរគំនិតគ្នាទៅវិញទៅមក បទពិសោធន៍ជាក់ស្តែង និង មតិយោបល់អំពីវិធីប្រសើរបំផុតសម្រាប់ដោះស្រាយបញ្ហារំលោភបំពានទៅលើសុចរិតភាព ទាំងខាងក្នុង និងខាងក្រៅ។
- ដើម្បីផ្តល់ដំបូន្មានឯករាជ្យជូនថ្នាក់គ្រប់គ្រង ឬ នាយកដ្ឋាន/ការិយាល័យពាក់ព័ន្ធ អំពីសុចរិតភាព ឬ បញ្ហាកង្វល់ទាក់ទងនឹងការលាងប្រាក់/ហិរញ្ញប្បទានភេរវកម្ម (ML/FT) រាប់បញ្ចូលការស៊ើបអង្កេតដើម្បីសម្របសម្រួលដល់លទ្ធភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការវាយតម្លៃទៅលើបញ្ហាកង្វល់ ទាក់ទងនឹងសុចរិតភាព ឬ ការលាងប្រាក់/ហិរញ្ញប្បទានភេរវកម្មដែលមានលក្ខណៈគួរឱ្យកត់សម្គាល់។
- ដើម្បីផ្តល់ការណែនាំជូននាយកដ្ឋាន/ការិយាល័យពាក់ព័ន្ធអំពីសុចរិតភាព និង ហានិភ័យទាក់ទងនឹងការលាងប្រាក់/ហិរញ្ញប្បទានភេរវកម្ម និង ការប្រុងប្រយ័ត្នយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាសុចរិតភាព ដែលគ្របដណ្តប់ទៅលើការត្រួតពិនិត្យការលាងប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។

៧. ការិយាល័យស៊ើបអង្កេត ត្រូវចាត់វិធានការសមស្រប ដើម្បីជួយរក្សាការសម្ងាត់ចំពោះព័ត៌មានឯកជនដែលទាក់ទងនឹងការស៊ើបអង្កេត រួមទាំងអត្តសញ្ញាណរបស់ភាគីដែលជាគោលដៅនៃការស៊ើបអង្កេត និងអត្តសញ្ញាណរបស់ភាគីផ្តល់វត្ថុតាង និងភស្តុតាង ។ បែបបទនៃការរក្សាទុកព័ត៌មាន និង

ការផ្តល់ព័ត៌មានឱ្យភាគីនៅក្នុងអង្គការ និងភាគីនៅក្រៅអង្គការរួមទាំងអាជ្ញាធរជាតិ មានចែងនៅក្នុងច្បាប់គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៧.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវរក្សាព័ត៌មាន និងឯកសារនានារបស់ខ្លួន ដោយមានការត្រួតពិនិត្យជាលក្ខណៈរូបវ័ន្ត អេឡិចត្រូនិច និងមាននីតិវិធីគ្រប់គ្រាន់។ OAI នឹងកំហិតការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត ដូចជា កម្មវត្ថុនៃការស៊ើបអង្កេត និងអត្តសញ្ញាណរបស់ភាគី ដោយផ្តល់ព័ត៌មានដល់អ្នកដែលចាំបាច់ត្រូវដឹងតែប៉ុណ្ណោះ។ អាស្រ័យទៅតាមលក្ខណៈរបស់ករណីជាក់ស្តែង OAI អាចបង្ហាញនូវភស្តុតាងមួយចំនួន ដល់អ្នកដែលកំពុងទទួលរងការស៊ើបអង្កេត[10] ក្នុងលក្ខណៈមួយដែលផ្តល់ការការពារដល់អ្នកផ្តល់ព័ត៌មាន និងសាក្សី ដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.១០។

៧.ខ. មានតែ OAI និងប្រធានធនាគារតែប៉ុណ្ណោះ ដែលអាចចូលមើលឯកសារ និងកំណត់ត្រានានារបស់ OAI បាន។ OAI ឬប្រធានធនាគារ អាចធ្វើការសម្រេចចិត្តថាតើឯកសារ និងកំណត់ត្រានានារបស់ OAI អាចចែករំលែក ដោយមិនកែសម្រួល ឬមិនដាក់កាលបរិច្ឆេទជាថ្មីទៅឱ្យភាគីផ្សេងទៀតបានដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.០៤, បញ្ជារដ្ឋបាល ២.១០, គោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈ និង វិធានដែលពាក់ព័ន្ធដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

10 “អ្នកទទួលរងការស៊ើបអង្កេត” សំដៅលើភាគី ដែលត្រូវបានគេចោទប្រកាន់ថាបានចូលរួមនៅក្នុងការប្រព្រឹត្តល្មើសនឹងសុចរិតភាព និង/ឬការប្រព្រឹត្តមិនត្រឹមត្រូវដែល OAI កំពុងស៊ើបអង្កេត។

៨. លទ្ធផលនៃការស៊ើបអង្កេត ត្រូវផ្អែកលើអង្គហេតុ និងការវិភាគដែលស៊ីសង្វាក់គ្នា ដែលរួមទាំងការពិចារណាសមហេតុផលផងដែរ ។

៩. ការិយាល័យស៊ើបអង្កេត ត្រូវផ្តល់អនុសាសន៍ដែលបានមកពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ដោយមានហេតុផលច្បាស់លាស់ ជូនដល់ថ្នាក់ដឹកនាំរបស់អង្គការ ។

១០. គ្រប់ការស៊ើបអង្កេតដែលបានធ្វើឡើងដោយការិយាល័យស៊ើបអង្កេត ត្រូវមានលក្ខណៈរដ្ឋបាលត្រឹមត្រូវ ។

## និយមន័យ

១១. អំពើមិនគប្បី គឺជាការខកខានរបស់បុគ្គលិកក្នុងការគោរពតាមបទបញ្ញត្តិប្រតិបត្តិ ឬ បទដ្ឋានឥរិយាបទដែលកំណត់ដោយអង្គការ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១១.ក ក្រមសីលធម៌ និងស្តង់ដានៃការប្រព្រឹត្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានចែងនៅក្នុងបញ្ជារដ្ឋបាល ២.០[11]។វិធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលគ្របដណ្តប់លើការប្រព្រឹត្តមិនត្រឹមត្រូវ មានចែងនៅក្នុងបញ្ជារដ្ឋបាល ២.០៤[12]។

11 គោលនយោបាយបុគ្គលិក និងភារកិច្ច សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គលិក។

12 ស្ថិតក្រោម AO 2.10 (ការការពារអ្នកផ្តល់ព័ត៌មាន និងសាក្សី) ការសងសឹកគឺជាអំពើខុសឆ្គង ហើយបុគ្គលទាំងឡាយណាដែលចូលរួមនៅក្នុងការសងសឹក ត្រូវទទួលទណ្ឌកម្មតាមប្បញ្ញត្តិវិន័យក្រោម AO 2.04។

១២. បទដ្ឋាននៃភស្តុតាងដែលនឹងត្រូវប្រើប្រាស់ដើម្បីកំណត់ថាតើបណ្តឹងមួយមានភស្តុតាងត្រឹមត្រូវឬគ្មាន គឺត្រូវបានគេកំណត់ជានិយមន័យមួយឡើងដើម្បីធ្វើការស៊ើបអង្កេត ។ ជាទូទៅ និយមន័យនេះ គឺជាព័ត៌មានដែលបញ្ជាក់ថា អាចមានបញ្ហាអ្វីមួយកើតឡើងពិតប្រាកដជាងមិនអាចមាន ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១២.ក ធនាគារអភិវឌ្ឍន៍អាស៊ី អាចចាត់ទុកបទដ្ឋាននៃភស្តុតាងនេះថា ជាប្រភេទមួយនៃភស្តុតាង ឬជាភស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការជឿជាក់យ៉ាងសមហេតុសមផលថា ភាគីមួយបានប្រព្រឹត្តល្មើសក្នុងករណីបំពានសុចរិតភាពណាមួយ ដោយធ្វើការពិចារណាពីគ្រប់កត្តា និងកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់។

## សិទ្ធិ និងកាតព្វកិច្ច

### *សាក្សី និងគោលដៅ*

១៣. សមាជិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា“អ្នកផ្តល់ប្រភពព័ត៌មាន” ស្ថិតក្រោមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ មិនត្រូវក្លាយជាគោលដៅនៃការសងសឹករបស់អង្គការទេ។ អង្គការ នឹងចាត់ទុកការសងសឹកនេះ ថាជាអំពើមិនគប្បីមួយផ្សេងទៀត ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១៣.ក. ការផ្តល់ការការពារដល់អ្នកផ្តល់ព័ត៌មាន និងសាក្សីត្រូវកំណត់ដោយបញ្ញារដ្ឋបាល ២.១០។

១៤. អង្គការ នឹងតម្រូវឱ្យបុគ្គលិករាយការណ៍អំពីសកម្មភាពដែលគួរឱ្យសង្ស័យនៃការគៃបន្លំ អំពើពុករលួយ និងទម្រង់ផ្សេងទៀតនៃអំពើមិនគប្បី។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១៤.ក បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានកាតព្វកិច្ចរាយការណ៍ពីករណីសង្ស័យថា មានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ទៅកាន់ OAI។ បុគ្គលិកទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀតទៅកាន់ BPMSD ដោយអនុលោមទៅតាមបញ្ជារដ្ឋបាល ២.១០។ បុគ្គលិកអាចរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវបានដោយមិនចាំបាច់សុំការឯកភាព ឬការអនុញ្ញាតជាមុន។

១៥. អង្គការតម្រូវឱ្យបុគ្គលិកទាំងអស់ចូលរួមសហការនៅក្នុងការស៊ើបអង្កេត និងឆ្លើយសំណួរផ្សេងៗព្រមទាំងអនុវត្តតាមការស្នើសុំព័ត៌មាននានា ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

១៥.ក. បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី[13] មានភារកិច្ចសហការពេញលេញនៅក្នុងការពិនិត្យ ឬការស៊ើបអង្កេតអ្វីមួយ នៅពេលដែលមានការស្នើសុំពី OAI។ ការសហការបែបនេះរួមមាន ប៉ុន្តែមិនមែនកំហិតត្រឹមតែចំណុចខាងក្រោមឡើយ ៖

តទៅទំព័របន្ទាប់

13 ចំណុចនេះអនុវត្តចំពោះកម្មវត្ត និងសាក្សី។

ប្រអប់បន្តទៀត

- មានវត្តមានឱ្យគេសម្ភាស និង ឆ្លើយចំពោះសំណួរទាំងអស់ដែលបានសួរ ដោយពេញលេញ និងដោយស្មោះត្រង់។
- ផ្តល់ឱ្យ OAI នូវអ្វីៗដែលត្រូវបានស្នើសុំ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលិករូបនោះ ដូចជា ប៉ុន្តែ មិនកំហិតត្រឹម ឯកសារ និងវត្ថុរូបវ័ន្តផ្សេងទៀត។
- សហការនៅក្នុងការធ្វើតេស្តនានា ដែលស្នើឡើងដោយ OAI ដូចជា ប៉ុន្តែមិនកំហិតត្រឹមការកំណត់អត្តសញ្ញាណស្នាំម្រាមដៃ ការវិភាគលើការសរសេរដោយដៃ និងការពិនិត្យ និងវិភាគជាលក្ខណៈរូបវ័ន[14]។
- ការរក្សា និងការពារការសម្ងាត់នៃគ្រប់ព័ត៌មានទាំងអស់ ដែលត្រូវបានពិភាក្សាជាមួយ OAI នឹង BPMSD។

១៥.ខ. បុគ្គលិក ដែលស្ថិតក្រោមការស៊ើបអង្កេត ត្រូវផ្តល់លទ្ធភាពឱ្យមានការផ្តល់ព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន ដោយផ្ទាល់ទៅកាន់ OAI ប្រសិនបើមានការស្នើសុំបែបនេះ។ បន្ទាប់ពីមានការស្នើពី OAI បុគ្គលិកត្រូវផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរដល់ស្ថាប័នហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីបដិសេធចោលនូវសិទ្ធិរក្សាភាពជាឯកជន ឬការរក្សាការសម្ងាត់របស់បុគ្គលិក ពាក់ព័ន្ធជាមួយនឹងព័ត៌មានដែលត្រូវបង្ហាញ។

១៥.គ. បុគ្គលិក ដែលស្ថិតក្រោមការស៊ើបអង្កេត អាចស្នើសុំឱ្យបុគ្គលិក

តទៅទំព័របន្ទាប់

14 មិនមែនជាល័ក្ខខ័ណ្ឌតម្រូវជាកំហិតសម្រាប់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីដែលជាសាក្សី។

ប្រអប់បន្តទៀត

ម្នាក់ទៀតនៅអមជាមួយខ្លួន[15] នៅក្នុងពេលធ្វើការសម្ភាសន៍ ដែលជាផ្នែកមួយនៃការស៊ើបអង្កេត ដរាបណាការស្នើបែបនេះ មិនធ្វើឱ្យមានការពន្យារពេល ឬ រាំងស្ទះដល់ការស៊ើបអង្កេត។ ប៉ុន្តែ បុគ្គលិកដែលនៅអមនេះមិនអាចជាបុគ្គលិករបស់ OAI, OGC, ការិយាល័យលេខាធិការ, ការិយាល័យអគ្គសវនករ, ការិយាល័យសេវារដ្ឋបាល ឬ BPMSD បានឡើយ។ ទាំងបុគ្គលិក ទាំងសាក្សី អាចពិគ្រោះយោបល់ជាមួយនឹងទីប្រឹក្សាច្បាប់ខាងក្រៅអំពីបញ្ហា ដែលកំពុងត្រូវបានស៊ើបអង្កេត ដោយរ៉ាប់រងសោហ៊ុយនានា ដោយខ្លួនឯង ប៉ុន្តែ មិនអាចឱ្យទីប្រឹក្សាច្បាប់រូបនេះនៅអមក្នុងបរិវេណការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី ឬក្នុងពេលសម្ភាស ដែលជាផ្នែកមួយនៃការស៊ើបអង្កេតនេះបានឡើយ។ ការពិគ្រោះយោបល់បែបនេះមិនត្រូវពន្យារពេលការសម្ភាស ឬការអនុលោមរបស់បុគ្គលិកទៅតាមកាតព្វកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រោមវិធានទាំងនេះឡើយ លើកលែងតែមានការអនុញ្ញាតពី OAI។

១៥.ឃ ប្រសិនបើសមាជិកម្នាក់មិនអនុលោមទៅតាមកាតព្វកិច្ចដែលតម្រូវឱ្យមានការសហការនោះ ធនាគារអភិវឌ្ឍន៍អាស៊ីអាចចាត់ទុកការបដិសេធបែបនេះ ថាជាចំណុចអវិជ្ជមានមួយ។ នៅក្នុងករណីបែបនេះ OAI អាចបញ្ជូនករណីនេះទៅកាន់ BPMSD ដើម្បីចាត់វិធានការវិន័យដែលសមស្រប អនុលោមទៅតាម AO ២.០៤។ ការខកខានមិនសហការ រួមមានការមិនឆ្លើយតបទាន់ពេលវេលា និងមិន

តទៅទំព័របន្ទាប់

15 ឈ្មោះរបស់បុគ្គលិកដែលនៅអមជាមួយ គប្បីផ្ដល់ជូនការិយាល័យ OAI ជាមុន។ OAI មានឆន្ទានុសិទ្ធិក្នុងការមិនអនុញ្ញាតឱ្យមានវត្តមានចូលរួមពីបុគ្គលិកនោះ និងស្នើសុំឱ្យបុគ្គលិកផ្សេងជំនួស។

ប្រអប់បន្តទៀត

បានពេញលេញចំពោះសំណួររបស់ OAI, ការខកខានមិនផ្តល់ឯកសារ ឬភស្តុតាងដទៃទៀត ដែលស្នើសុំដោយ OAI, ការបំផ្លាញ ឬការលាក់បាំងភស្តុតាង ឬការក្លែងបន្លំព័ត៌មាន ក្នុងកំឡុងការស៊ើបអង្កេត ឬធ្វើឱ្យមានការរាំងស្ទះដល់ការស៊ើបអង្កេតរបស់ OAI។

១៦. អង្គការនីមួយៗ ត្រូវអនុវត្តតាមច្បាប់ គោលនយោបាយនិងនីតិវិធីនានា ហើយដោយស្ថិតក្នុងកម្រិតមួយសមស្របទៅតាមក្របខ័ណ្ឌនៃច្បាប់ និងពាណិជ្ជកម្មអង្គការទាំងនោះ ត្រូវបន្ថែមការអនុវត្តទៅលើកិច្ចសន្យាជាមួយភាគីទីបីជាផ្នែកដែលភាគីពាក់ព័ន្ធនៅក្នុងដំណើរការស៊ើបអង្កេតត្រូវសហប្រតិបត្តិការក្នុងការស៊ើបអង្កេត ។

១៧. អ្នកដែលជាគោលដៅនៃការស៊ើបអង្កេតខ្លួនឯង គឺជាផ្នែកមួយនៃដំណើរការស៊ើបអង្កេត ហើយត្រូវបានគេផ្តល់ឱកាសឱ្យពន្យល់បកស្រាយនូវការប្រព្រឹត្ត និងឱ្យលាតត្រដាងព័ត៌មានរបស់ខ្លួន ។ ច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ គឺជាអ្នកកំណត់ពេលវេលានៃការផ្តល់ឱកាសដល់អ្នកដែលជាគោលដៅនេះ។

## ***ការិយាល័យស៊ើបអង្កេត***

១៨. ការស៊ើបអង្កេត គួរតែធ្វើឡើងឱ្យបានឆាប់រហ័ស ទៅតាមកម្រិតធនធាន។

១៩. ការិយាល័យស៊ើបអង្កេត គួរតែត្រួតពិនិត្យទាំងព័ត៌មានដែលនាំឱ្យមានការចោទប្រកាន់ និងព័ត៌មានដែលនាំឱ្យរួចផុតពីការចោទប្រកាន់ ។

២០. ការិយាល័យស៊ើបអង្កេត ត្រូវរក្សានិងការពារសុវត្ថិភាពឱ្យបានល្អ នូវកំណត់ត្រានៃការស៊ើបអង្កេតនិងព័ត៌មានផ្សេងៗដែលប្រមូលបាន ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

២០.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព ត្រូវរក្សា ៖

- ឯកសារនៃការស៊ើបអង្កេត ដែលពាក់ព័ន្ធជាមួយនឹងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី តិចបំផុតរយៈពេល ១០ ឆ្នាំ ក្រោយពីពេលដែលបុគ្គលិករូបនេះចេញពីធនាគារអភិវឌ្ឍន៍អាស៊ី រហូតដល់បុគ្គលិកនោះមានអាយុ ៧០ ឆ្នាំ ឬកាលៈទេសៈដែលធនាគារអភិវឌ្ឍន៍អាស៊ី នឹងមិនពិចារណាជួលបុគ្គលិករូបនោះ ម្តងទៀត។
- ឯកសារអំពីការស៊ើបអង្កេតផ្សេងទៀត តិចបំផុតរយៈពេល ១០ ឆ្នាំ ចាប់ពីពេលទទួលពាក្យបណ្តឹង។
- ឯកសារអំពីការពិនិត្យឡើងវិញពាក់ព័ន្ធនឹងលទ្ធកម្មគម្រោងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីមានការចេញរបាយការណ៍។
- កិច្ចសន្យាពាក់ព័ន្ធនឹងទីប្រឹក្សា ដែលបានជួលឱ្យធ្វើសវនកម្ម និងការស៊ើបអង្កេត តិចបំផុតរយៈពេល ៥ ឆ្នាំ បន្ទាប់ពីការបញ្ចប់កិច្ចសន្យា។
- លិខិតឆ្លើយឆ្លង ដូចជា លិខិតពីការិយាល័យមួយ ទៅការិយាល័យមួយទៀត និងអនុសាសន៍នានាដល់អ្នកគ្រប់គ្រង តិចបំផុត ៥ ឆ្នាំ។
- របាយការណ៍ប្រចាំឆ្នាំរបស់ OAI ជូនប្រធានធនាគារ ទុកជារៀងរហូត។

២១. បុគ្គលិករបស់ការិយាល័យស៊ើបអង្កេត ត្រូវចាត់វិធានការសមស្របដើម្បីបង្ការការផ្សព្វផ្សាយព័ត៌មាននៃការស៊ើបអង្កេត ដោយគ្មានការអនុញ្ញាត។

២២. ការិយាល័យស៊ើបអង្កេត ត្រូវចងក្រងជាឯកសារនូវលទ្ធផល និងសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតរបស់ខ្លួន។

២៣. ក្នុងគោលបំណងនៃការស៊ើបអង្កេត ការិយាល័យស៊ើបអង្កេត ត្រូវមានលទ្ធភាពពេញលេញ និងគ្រប់គ្រាន់ដើម្បីប្រមូលព័ត៌មាន កំណត់ត្រា បុគ្គលិក និងទ្រព្យសម្បត្តិដែលពាក់ព័ន្ធរបស់អង្គការ ដោយអនុលោមទៅតាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

២៣.ក. បញ្ញារដ្ឋបាល ១.០២[16] ដែលអាចអនុវត្តបានចំពោះ OAI និងលក្ខខណ្ឌយោងរបស់ OAI ផ្តល់ឱ្យ OAI នូវលទ្ធភាពចូលមើលព័ត៌មាន និងឯកសារនានា ពាក់ព័ន្ធនឹងសកម្មភាពទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី យ៉ាងពេញលេញ និងដោយគ្មានការកំហិតអ្វីទាំងអស់។ OAI អាចពិនិត្យមើលគ្រប់ឯកសារ កំណត់ត្រា សៀវភៅ ទិន្នន័យ ក្រដាសស្នាមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងឯកសារផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹងសកម្មភាពនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមការចាំបាច់ និងនៅពេលដែលចាំបាច់ អាចកាន់កាប់ឯកសារទាំងនោះជាបណ្តោះអាសន្ន និងធ្វើការថតចម្លង។

តទៅទំព័របន្ទាប់

16 ព្រឹត្តបត្រព័ត៌មានរបស់ស្ថាប័ន។

ប្រអប់បន្តទៀត

២៣.ខ. សំណើសុំមើលអ៊ីមែល ដែលស្នើឡើងដោយ OAI ត្រូវបំពេញស្របទៅតាមបញ្ញារដ្ឋបាល ៤.០៥។[17]

២៤. តាមរយៈខ្លឹមសារដែលចែងក្នុងច្បាប់ គោលនយោបាយ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកិច្ចសន្យាពាក់ព័ន្ធ ការិយាល័យស៊ើបអង្កេតមានអំណាចត្រួតពិនិត្យ និងថតចម្លងសៀវភៅ និងកំណត់ត្រាដែលពាក់ព័ន្ធនៃគម្រោង បុគ្គល ភ្នាក់ងារប្រតិបត្តិ ឬក្រុមហ៊ុនដែលកំពុងចូលរួម ឬកំពុងព្យាយាមចូលរួមក្នុងសកម្មភាពដែលផ្ដល់ហិរញ្ញប្បទានដោយអង្គការ ឬអង្គភាពណាមួយផ្សេងទៀត ដែលចូលរួមក្នុងការចាយវាយមូលនិធិរបស់អង្គការ ។

២៥. ការិយាល័យស៊ើបអង្កេតអាចពិគ្រោះយោបល់និងសហការជាមួយអង្គការស្ថាប័នអន្តរជាតិ និងភាគីផ្សេងទៀតដែលពាក់ព័ន្ធដើម្បីផ្លាស់ប្ដូរយោបល់បទពិសោធន៍ និងការស្វែងយល់អំពីដំណោះស្រាយដ៏ល្អបំផុត លើបញ្ហាព្រួយបារម្ភទៅវិញទៅមក ។

២៦. ការិយាល័យស៊ើបអង្កេត អាចផ្ដល់ជំនួយ និង ចែករំលែកព័ត៌មានទៅឱ្យការិយាល័យស៊ើបអង្កេតផ្សេងទៀត ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

២៦.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ឬប្រធានធនាគារ អាចកំណត់ថាតើ ព័ត៌មាននានា ដូចជា ព័ត៌មានដែលទទួលបានក្នុងពេលធ្វើការស៊ើបអង្កេត អាចត្រូវបានចែករំលែកជាមួយ

តទៅទំព័របន្ទាប់

17 គោលការណ៍ស្ដីពីបច្ចេកវិទ្យា និងទំនាក់ទំនង។

ប្រអប់បន្តទៀត

អង្គការអន្តរជាតិដទៃទៀត តំណាង ឬទីភ្នាក់ងាររបស់ប្រទេសជាសមាជិកធនាគារអភិវឌ្ឍន៍អាស៊ី ឬភាគីដទៃទៀត ដែលចាំបាច់ត្រូវដឹងពីព័ត៌មានទាំងនេះ ដើម្បីប្រយោជន៍នៃការសហការ ការធ្វើសុខុដុមកម្ម ឬកត្តាពាក់ព័ន្ធដទៃទៀត ទៅតាមបញ្ជារដ្ឋបាល ២.០៤, បញ្ជារដ្ឋបាល ២.១០, គោលនយោបាយស្ដីពីការប្រាស្រ័យទាក់ទងសាធារណៈ និងវិធានពាក់ព័ន្ធដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ។ នៅក្នុងករណី ដែល OAI សម្រេចចិត្តចែករំលែកព័ត៌មាននេះ OAI ត្រូវតម្រូវឱ្យអ្នកទទួលព័ត៌មាននេះផ្ដល់ការការពារដល់ការសម្ងាត់របស់ព័ត៌មាន ហើយប្រើប្រាស់ព័ត៌មាននេះ តែសម្រាប់គោលបំណងរបស់ OAI នៅក្នុងការបង្ហាញព័ត៌មាននេះ តែប៉ុណ្ណោះ។

២៦.ខ.OAI អាចសហការ នៅក្នុងការស៊ើបអង្កេតជាមួយអង្គការ ការិយាល័យ ឬភាគីនានាបាន ដរាបណា ការសហការនេះមិនមានឥទ្ធិពលលើឯករាជ្យភាព និងភាពសត្យានុម័តរបស់ OAI ឬធ្វើឱ្យប៉ះពាល់ដល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្របទៅតាមធម្មនុញ្ញរបស់ធនាគារនេះ។

# សេចក្ដីណែនាំអំពីនីតិវិធី

## *ប្រភពនៃបណ្ដឹង*

២៧. ការិយាល័យស៊ើបអង្កេត ត្រូវទទួលគ្រប់ពាក្យបណ្ដឹងទាំងអស់ ដោយមិនគិតដល់ប្រភព រួមទាំងពាក្យបណ្ដឹងអនាមិក ឬពាក្យបណ្ដឹងសម្ងាត់ផងដែរ។

២៨. ការិយាល័យស៊ើបអង្កេត ត្រូវតែទទួលស្គាល់នូវការទទួលពាក្យបណ្ដឹងទាំងអស់ ប្រសិនបើអាចធ្វើបាន ។

## *ការទទួលពាក្យបណ្ដឹង*

២៩. ពាក្យបណ្ដឹងទាំងអស់នឹងត្រូវចុះបញ្ជី និងពិនិត្យមើលឡើងវិញដើម្បីសម្រេចថា តើពាក្យបណ្ដឹងទាំងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចឬអំណាចរបស់ការិយាល័យស៊ើបអង្កេតដែរឬទេ ។

## *ការវាយតម្លៃបឋម*

៣០. នៅពេលដែលពាក្យបណ្ដឹងត្រូវបានចុះក្នុងបញ្ជី ការិយាល័យស៊ើបអង្កេតពាក្យបណ្ដឹងនោះ នឹងត្រូវការិយាល័យស៊ើបអង្កេតធ្វើការវាយតម្លៃដើម្បីកំណត់ភាពដែលអាចជឿបាន ភាពចាំបាច់ និងភាពដែលអាចផ្ទៀងផ្ទាត់បាន ។ ជាចុងបញ្ចប់ ពាក្យបណ្ដឹង នឹងត្រូវគេពិនិត្យដើម្បីសម្រេចថា តើមានមូលដ្ឋានស្របច្បាប់ណាមួយដើម្បីធានាចំពោះការស៊ើបអង្កេតដែរឬទេ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៣០.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ធ្វើការវាយតម្លៃ ឬ “ត្រួតពិនិត្យ” ពាក្យបណ្ដឹងនានា ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីកំណត់ថាតើពាក្យបណ្ដឹងទាំងនេះត្រូវមានការស៊ើបអង្កេតបន្តដែរឬទេ។ ពាក្យបណ្ដឹងគួរមានការចោទប្រកាន់ ឬ ព័ត៌មានដែល ៖

- ស្ថិតក្នុងក្របខ័ណ្ឌអាណត្តិការងាររបស់ OAI - ពោលគឺពាក់ព័ន្ធ

តទៅទំព័របន្ទាប់

ប្រអប់បន្តទៀត

ជាមួយនឹងសកម្មភាព ដែល OAI ត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត។

- អាចជឿជាក់បាន - ពោលគឺមានលទ្ធផលសមស្រប ដែលថាការប្រព្រឹត្តល្មើសមួយអាចកើតមានឡើង។
- អាចផ្ទៀងផ្ទាត់បាន - ពោលគឺមានជម្រើស ដែលអាចទទួលបានភស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់ពីភាពពិតប្រាកដនៃការចោទប្រកាន់។
- មានសារៈសំខាន់ - ពោលគឺបញ្ហា ដែលតម្រូវឱ្យមានការស៊ើបអង្កេតនេះ មានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីកំណត់ពីភាពសមហេតុសមផលនៃការតម្រូវឱ្យមានការស៊ើបអង្កេត និងសកម្មភាពកែតម្រូវនានា។
- កត្តាដែលពាក់ព័ន្ធផ្សេងទៀត ឧ. ថាតើបញ្ហានេះអាចត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព តាមរយៈជម្រើស ដែលធនាគារអភិវឌ្ឍន៍អាស៊ីមានដែរឬទេ។

៣០.ខ. នៅពេលបញ្ចប់ការត្រួតពិនិត្យមួយ បុគ្គលិករបស់ OAI ត្រូវផ្តល់អនុសាសន៍ដល់ប្រធានការិយាល័យ OAI ឬតំណាងរបស់គាត់ ថាតើត្រូវបិទពាក្យបណ្តឹងនេះ ឬត្រូវមានការស៊ើបអង្កេតបន្ថែមទៀត។ ការសម្រេចចិត្ត ដើម្បីបិទ ឬត្រូវស៊ើបអង្កេតបន្ថែមទៀត ត្រូវមានការចងក្រងទុកជាឯកសារត្រឹមត្រូវ ដោយមានរបាយការណ៍ ដែលទទួលបានការឯកភាព ដោយមានបង្ហាញពីមូលហេតុ ដែលធ្វើឱ្យមានការសម្រេចចិត្តបែបនេះ។ ព័ត៌មាន ដែលពាក់ព័ន្ធជាមួយនឹងពាក្យបណ្តឹង ត្រូវរក្សាទុកក្នុងឯកសាររបស់ OAI។

តទៅទំព័របន្ទាប់

ប្រអប់បន្តទៀត

៣០.គ. ប្រសិនបើពាក្យបណ្តឹងមួយពាក់ព័ន្ធជាមួយនឹងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី OAI អាចសម្របសម្រួលការស៊ើបអង្កេតជាមួយនឹង BPMSD ដោយពិចារណាលើបញ្ហារដ្ឋបាលដែលពាក់ព័ន្ធ រួមទាំងលក្ខណៈ នៃការប្រព្រឹត្តមិនត្រឹមត្រូវ ដែលអាចកើតមានឡើង។ OAI ត្រូវធ្វើបែបនេះ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងតាមបែបផែន ដែលមិនមានឥទ្ធិពលលើឯករាជ្យភាព និងភាពសត្យានុម័តរបស់ OAI។

### *ការផ្តល់អាទិភាពចំពោះករណីនៃពាក្យបណ្តឹង*

៣១. សេចក្តីសម្រេចនានាសម្រាប់បន្តការស៊ើបអង្កេត ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ឯសេចក្តីសម្រេចសម្រាប់ប្រើប្រាស់សកម្មភាពស៊ើបអង្កេតក្នុងពាក្យបណ្តឹង ត្រូវអាស្រ័យលើការិយាល័យស៊ើបអង្កេត ។

៣២. ការរៀបចំផែនការ និងដំណើរការនៃការស៊ើបអង្កេត ព្រមទាំងធនធានសម្រាប់ប្រើប្រាស់ក្នុងការស៊ើបអង្កេត ត្រូវពិចារណាដល់ទម្ងន់នៃការចោទប្រកាន់ និងលទ្ធផលដែលអាចទទួលបាន ។

### *សកម្មភាពស៊ើបអង្កេត*

៣៣. ការិយាល័យស៊ើបអង្កេត ត្រូវស្វែងរកបន្ថែមទៀត នូវព័ត៌មានលម្អិតដែលខ្លួនមាន ប្រសិនបើអាចធ្វើបាន ។

៣៤. សម្រាប់គោលបំណងនៃការស៊ើបអង្កេត សកម្មភាពស៊ើបអង្កេត រួមមានការប្រមូល និងការវិភាគព័ត៌មានតាមឯកសារ វីដេអូ សម្លេង រូបភាព និងតាមអេឡិចត្រូនិច ឬសម្ភារៈផ្សេងៗ ការសម្ភាសន៍សាក្សី ការឃ្លាំមើលរបស់អ្នកស៊ើបអង្កេត និងបច្ចេកទេសស៊ើបអង្កេតផ្សេងទៀត ដែលចាំបាច់ដើម្បីធ្វើការស៊ើបអង្កេត ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៣៤.ក. ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាពអាចប្រមូលភស្តុតាងជាឯកសារ វីដេអូ រូបថត ការវិភាគក្នុងកុំព្យូទ័រ ឬខ្សែអាត់សម្លេង ដែលពាក់ព័ន្ធនឹងប្រធានបទនៃការស៊ើបអង្កេត ដោយមិនចាំបាច់ជូនដំណឹងជាមុន ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដរាបណាសកម្មភាពទាំងនេះ ស្របទៅតាមវិធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៣៥. សកម្មភាពស៊ើបអង្កេត និងសេចក្ដីសម្រេចសំខាន់ៗនានា គួរតែចងក្រងជាឯកសារដោយមានលាយលក្ខណ៍អក្សរ ហើយប្រធានការិយាល័យស៊ើបអង្កេតត្រូវពិនិត្យមើលឡើងវិញ ។

៣៦. តាមច្បាប់ គោលនយោបាយ និងនីតិវិធីរបស់អង្គការ ទោះបីក្នុងពេលណាមួយក៏ដោយក្នុងកំឡុងពេលកំពុងស៊ើបអង្កេត ប្រសិនបើការិយាល័យស៊ើបអង្កេតយល់ថា ការិយាល័យគួរចាត់ឱ្យមានវិធានការប្រុងប្រយ័ត្នជាមុន ឬ ដើម្បីការពារព័ត៌មានរារាំងជាបណ្ដោះអាសន្នមិនឱ្យសមាជិកដែលជាគោលដៅនៃការស៊ើបអង្កេតអាចទទួលបានឯកសារ ឬចូលទៅកាន់ការិយាល័យរបស់ខ្លួន ឬផ្ដល់អនុសាសន៍ឱ្យព្យួរការងារ ដោយផ្ដល់ ឬមិនផ្ដល់ប្រាក់កម្រៃ និងផលប្រយោជន៍ផ្សេងៗ ឬផ្ដល់អនុសាសន៍ដាក់

កំហិតលើសកម្មភាពផ្លូវការរបស់គេ ការិយាល័យត្រូវបញ្ជូនបញ្ហានេះទៅអាជ្ញាធរពាក់ព័ន្ធក្នុងអង្គការដើម្បីចាត់វិធានការសមស្រប ។

៣៧. បើសិនមានលទ្ធភាព ការិយាល័យស៊ើបអង្កេត ត្រូវរៀបចំឱ្យមានសមាជិកពីរនាក់ដើម្បីធ្វើការសម្ភាសន៍ ។

៣៨. តាមឆន្ទានុសិទ្ធិរបស់ការិយាល័យស៊ើបអង្កេត គេអាចប្រើភាសារបស់អ្នកដែលត្រូវសម្ភាសន៍ ក្នុងករណីមានអ្នកបកប្រែត្រឹមត្រូវ ។

៣៩. ការិយាល័យស៊ើបអង្កេត នឹងមិនបង់ប្រាក់ទៅឱ្យសាក្សី ឬអ្នកដែលជាគោលដៅដើម្បីបានទទួលព័ត៌មានឡើយ ។ តាមច្បាប់គោលនយោបាយ និងនីតិវិធីរបស់អង្គការ ការិយាល័យស៊ើបអង្កេតអាចទទួលខុសត្រូវលើកការចំណាយសមស្របរបស់សាក្សី ឬ ប្រភពព័ត៌មានផ្សេងទៀត ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ការិយាល័យស៊ើបអង្កេត ។

៤០. ការិយាល័យស៊ើបអង្កេត អាចទំនាក់ទំនងជាមួយភាគីខាងក្រៅ ដើម្បីចូលរួមសហការក្នុងការស៊ើបអង្កេតរបស់ខ្លួន ។

## លទ្ធផលនៃការស៊ើបអង្កេត

៤១. ក្នុងពេលស៊ើបអង្កេត ប្រសិនបើការិយាល័យស៊ើបអង្កេតមិនអាចរកព័ត៌មានគ្រប់គ្រាន់ ដើម្បីបង្ហាញភស្តុតាងចំពោះពាក្យបណ្តឹងនោះទេ ការិយាល័យនឹងចងក្រងលទ្ធផលនេះទុកជាឯកសារបញ្ចប់ការស៊ើបអង្កេត និងជូនដំណឹងដល់ភាគីពាក់ព័ន្ធតាមការគួរ ។

**ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ៖**

៤១.ក. ប្រធាន OAI និង នាយក OAI ទាំងពីរនាក់ ត្រូវឯកភាពដល់ការបិទករណីស៊ើបអង្កេតណាមួយ។ នៅក្នុងករណីដែលគេមិនអាចសុំការសុំការឯកភាពពីអ្នកទាំងពីរ ក្នុងរយៈពេលមួយសមស្របបាន បុគ្គលិកជាន់ខ្ពស់ OAI ដែលត្រូវបានចាត់តាំង អាចទទួលបានការអនុញ្ញាតឱ្យផ្តល់ការឯកភាពដល់ការសម្រេចចិត្ត ក្នុងនាមជាអាជ្ញាធរដែលមានសិទ្ធិផ្តល់ការឯកភាពបន្ទាប់ពីប្រធាន និងនាយករបស់ OAI។

៤២. ប្រសិនបើការិយាល័យស៊ើបអង្កេតអាចរកព័ត៌មានបានគ្រប់គ្រាន់ដើម្បីបង្ហាញភស្តុតាងចំពោះពាក្យបណ្តឹង ការិយាល័យនឹងចងក្រងលទ្ធផលនៃការស៊ើបអង្កេតទុកជាឯកសារ ហើយបញ្ជូនលទ្ធផលនៃការស៊ើបអង្កេតនេះ ទៅអាជ្ញាធរពាក់ព័ន្ធនៅក្នុងអង្គការ ស្របទៅតាមច្បាប់គោលនយោបាយ និងនីតិវិធីរបស់អង្គការ ។

៤៣. ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតបង្ហាញថា ពាក្យបណ្តឹងនេះមិនត្រឹមត្រូវ ការិយាល័យស៊ើបអង្កេតត្រូវបញ្ជូនបញ្ហានេះ ទៅឱ្យអាជ្ញាធរពាក់ព័ន្ធនៅក្នុងអង្គភាពតាមការគួរ ។

៤៤. ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតបង្ហាញថា សាក្សី ឬគោលដៅ មានការខកខានមិនបានគោរពតាមកាតព្វកិច្ចដែលមានចែងក្នុងដំណើរការស៊ើបអង្កេត ការិយាល័យស៊ើបអង្កេតអាចនឹងបញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងអង្គការ ។

## ការផ្តល់ព័ត៌មានទៅអាជ្ញាធរជាតិ

៤៥. ការិយាល័យស៊ើបអង្កេតអាចនឹងពិចារណាថា តើការផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងពាក្យបណ្តឹងទៅឱ្យអាជ្ញាធរជាតិមានសមត្ថកិច្ច ជាការសមស្របដែរឬទេ ហើយការិយាល័យស៊ើបអង្កេតនឹងសុំការអនុញ្ញាតផ្ទៃក្នុងដែលចាំបាច់ដើម្បីអនុវត្តបែបនេះ ក្នុងករណីដែលខ្លួនជឿជាក់ថា ការផ្តល់ព័ត៌មាននេះត្រូវបានធានា ។

## ការពិនិត្យមើលឡើងវិញ និងការធ្វើវិសោធនកម្ម

៤៦. រាល់ការធ្វើវិសោធនកម្មណាមួយចំពោះសេចក្តីណែនាំ ត្រូវអនុម័តដោយអង្គការតាមសម្លេងភាគច្រើន ។

## ការបោះពុម្ពផ្សាយ

៤៧. អង្គការណាក៏ដោយ អាចបោះពុម្ពគោលការណ៍ទាំងនេះ ដោយអនុលោមទៅតាមគោលនយោបាយស្តីពីការផ្សព្វផ្សាយព័ត៌មាន ។

# II. ទោសទណ្ឌ

## មូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវ

៤៨. ការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព អាចជាមូលដ្ឋានសម្រាប់ឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ចាត់វិធានការកែតម្រូវ រាប់បញ្ចូលទាំងការដាក់ទោសទណ្ឌផងដែរ។ ការប្រព្រឹត្តល្មើសនេះ រួមមាន ការប្រព្រឹត្តល្មើស ដែលអាចមិនពាក់ព័ន្ធនឹងសកម្មភាពពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។

៤៩. អនុលោមទៅតាមកិច្ចព្រមព្រៀងអំពីការសម្រេចចិត្តអំពីការអនុវត្តការហាមឃាត់ឱ្យគ្នាទៅវិញទៅមក[18] ធនាគារអភិវឌ្ឍន៍អាស៊ីអាចហាមឃាត់ភាគីទាំងឡាយណា ដែលត្រូវបានហាមឃាត់ដោយស្ថាប័នផ្សេងទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ ហើយស្ថាប័នផ្សេងទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ អាចហាមឃាត់ភាគីទាំងឡាយ ដែលត្រូវបានហាមឃាត់ជាសាធារណៈ ដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងដល់ស្ថាប័នផ្សេងទៀត ដែលចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ អំពីការសម្រេចចិត្តហាមឃាត់នីមួយៗ ដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍

18 ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០ ហើយត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់។

អាស៊ី ដែលស្ថិតនៅក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក និងការកែតម្រូវនានាដែលមាន។

៥០. ធនាគារអភិវឌ្ឍន៍អាស៊ីអាចចាត់ទុកថា ការសម្រេចចិត្តរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយទៀត ឬការសម្រេចចិត្តរបស់ស្ថាប័នច្បាប់ ឬនិយ័តកម្ម ដែលថាភាគីមួយខកខានមិនបានអនុលោមទៅតាមស្តង់ដាក្រមសីលធម៌សមស្រប ទៅតាមការកំណត់នៅក្នុងប្រព័ន្ធគោលការណ៍ វិធាន ឬភារកិច្ចនានា ដូចជា ច្បាប់ ឬបទប្បញ្ញត្តិរបស់រដ្ឋជាដើម ថាជាការខកខានរបស់ភាគីនោះ នៅក្នុងការរក្សានូវស្តង់ដាក្រមសីលធម៌ខ្ពស់បំផុត ដូចដែលបានតម្រូវដោយគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ភាគីនេះអាចត្រូវបានដាក់ឱ្យស្ថិតនៅក្រោមសកម្មភាពកែតម្រូវ អនុលោមទៅតាមគោលការណ៍ និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ។

៥១. ភាគីមួយត្រូវបានចាត់ទុកថា ជាភាគីដែលទទួលខុសត្រូវលើសកម្មភាព ឬការប៉ុនប៉ងប្រព្រឹត្តសកម្មភាពអ្វីមួយ ដែលអាចជាមូលដ្ឋាន សម្រាប់ការចាត់វិធានការកែតម្រូវ ដោយភាគីមួយទៀត រួមទាំង និយោជិត ភ្នាក់ងារ ឬតំណាង ដែលបំពេញការងារឱ្យភាគីនោះផង បើទោះបីជាសកម្មភាពនោះធ្វើឡើង ដោយមានការអនុញ្ញាតជាពិសេស ឬអត់ក៏ដោយ[19]។

---

19 ដើម្បីឱ្យអាចអនុវត្តទៅបាន កឋាខណ្ឌទី៥១ តម្រូវឱ្យ ៖ (១) កំណត់អំពីការរំលោភបំពានសុចរិតភាពមួយដែលប្រព្រឹត្តដោយនិយោជិត ឬ ភ្នាក់ងារណាម្នាក់ និង (២) បង្ហាញអំពីទំនាក់ទំនងរវាងនិយោជក-និយោជិត ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត-ភ្នាក់ងារ។ ក្នុងការអនុវត្តន៍ចំណុចនេះ OAI អាចពិចារណាអំពីកត្តាដទៃទៀត ដែលរួមមានជាអាទិ៍ កង្វះការត្រួតពិនិត្យផ្ទៃក្នុង ឬ ការអនុវត្តន៍ហិរញ្ញវត្ថុសមស្របរបស់ក្រុមហ៊ុនមួយ ចំណេះដឹងរបស់ថ្នាក់គ្រប់គ្រងកំពូល ឬ ការពាក់ព័ន្ធនៅក្នុងការរំលោភបំពានសុចរិតភាព ទំហំក្រុមហ៊ុន និង ប្រយោជន៍ដែលក្រុមហ៊ុនទទួលបាន។

៥២. ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវធានាឱ្យមានដំណើរការត្រឹមត្រូវ យុត្តិធម៌ និងសង្គតភាព ដោយមិនប្រើប្រាស់ដំណើរការតាមផ្លូវច្បាប់ ដែលមានចំពោះភាគី ដែលទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តអំពើពុករលួយ ឬការគៃបន្លំ នៅក្រោមប្រព័ន្ធច្បាប់ ឬតុលាការ។ នីតិវិធីរបស់ធនាគារអភិវឌ្ឍន៍-អាស៊ី មានលក្ខណៈជានីតិវិធីរដ្ឋបាល និងពុំមានលក្ខណៈជាដំណើរការច្បាប់ ឬតុលាការ ឬដូចដំណើរការច្បាប់ ឬតុលាការនោះឡើយ។

៥៣. ធនាគារអភិវឌ្ឍន៍អាស៊ីពុំមានគោលបំណងធ្វើឱ្យក្រុមហ៊ុន[20] ឬបុគ្គលណាលែងអាចប្រកបអាជីវកម្ម ដោយសារការដាក់ទោសទណ្ឌរបស់ខ្លួនឡើយ បើទោះបីជាហានិភ័យដែលការលែងអាចប្រកបអាជីវកម្មនេះ អាចកើតមានឡើង ក៏វាមិនអាចរារាំងមិនឱ្យធនាគារអភិវឌ្ឍន៍អាស៊ីដាក់ទោសទណ្ឌសមស្របបានទេ។

## ការជូនដំណឹងដល់ភាគី[21] ដែលស្ថិតនៅក្រោមការស៊ើបអង្កេត

### *បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

៥៤. ការជូនដំណឹងដល់បុគ្គលិក ដែលត្រូវស្ថិតនៅក្រោមការស៊ើបអង្កេត ត្រូវអនុលោមទៅតាមបញ្ញារដ្ឋបាល ២.០៤។

20 ពាក្យថា "ក្រុមហ៊ុន" ត្រូវបានប្រើប្រាស់ជាទូទៅ ហើយសំដៅដល់សាជីវកម្ម ស្ថាប័ន អង្គការ និងស្ថាប័នដទៃទៀត ដែលអាចមានស្ថានភាពផ្លូវច្បាប់ដោយឯករាជ្យ ឬអាចត្រូវបានបែងចែកដាច់ពីបុគ្គល ដែលបំពេញការងារនៅក្នុងស្ថាប័នទាំងនេះ។

21 ភាគីមួយអាចជាក្រុមហ៊ុន ឬបុគ្គល។

### *ភាគីដទៃទៀត*

៥៥. ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ភាគីណាមួយ ប្រព្រឹត្តល្មើសទៅនឹងសុចរិតភាព ការិយាល័យប្រឆាំងអំពើពុករលួយ និងសុចរិតភាព (OAI) ត្រូវចាត់វិធានការសមស្របគ្រប់បែបយ៉ាងទាំងអស់ ដើម្បីបង្ហាញពីលទ្ធផលរកឃើញទៅកាន់ភាគីនោះ ហើយផ្តល់លទ្ធភាពឱ្យភាគីនោះធ្វើការឆ្លើយតបមកវិញ។ នៅពេលទំនាក់ទំនងជាមួយភាគី OAI អាចពឹងអាស្រ័យលើសុក្រិតភាពនៃព័ត៌មាន ទំនាក់ទំនង ដែលភាគីនោះបានផ្តល់ដល់ធនាគារអភិវឌ្ឍន៍អាស៊ី។ ខណៈពេលដែល OAI ត្រូវធ្វើការខិតខំប្រឹងប្រែងសមស្របគ្រប់បែបយ៉ាង ដើម្បីទំនាក់ទំនងទៅកាន់ភាគី ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ការខកខានមិនបានទំនាក់ទំនងទៅកាន់ភាគីបើទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះក៏ដោយ នឹងមិនរារាំងធនាគារអភិវឌ្ឍន៍អាស៊ីមិនឱ្យដាក់ទោសទណ្ឌលើភាគីនេះបានឡើយ។

៥៦. នៅពេលបង្ហាញពីលទ្ធផលរកឃើញរបស់ខ្លួន ទៅកាន់ក្រុមហ៊ុនណាមួយ OAI ត្រូវជូនដំណឹងដល់ក្រុមហ៊ុននោះថា ធនាគារអភិវឌ្ឍន៍អាស៊ីអាចដាក់ទោសទណ្ឌលើអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត។ OAI ក៏ត្រូវជូនដំណឹងនិងបង្ហាញពីលទ្ធផលរកឃើញ និងអនុសាសន៍របស់ខ្លួន ដោយផ្ទាល់ទៅកាន់អ្នកទទួលខុសត្រូវ និងភាគីដែលពាក់ព័ន្ធទាំងនេះ អំពីសកម្មភាពកែតម្រូវ ដែលអាចនឹងត្រូវបានអនុវត្តលើពួកគេ ផងដែរ។

៥៧. ភាគីត្រូវមានឱកាសឆ្លើយតបចំពោះការចោទប្រកាន់ផ្សេងៗ និងចំពោះភស្តុតាង ដែលប្រឆាំងនឹងពួកគេ។ OAI អាចមិនបង្ហាញភស្តុតាង

ឬព័ត៌មានមួយចំនួន ប្រសិនបើមានមូលហេតុសមស្រប ដើម្បីធ្វើការសន្និដ្ឋានថា ការបង្ហាញពីភស្តុតាង ឬ ព័ត៌មាននេះ អាចបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិត សុខភាព សុវត្ថិភាព ឬ សុខុមាលភាពរបស់ភាគីណាមួយ ដូចជា អ្នកផ្តល់ព័ត៌មានជាដើម ឬ ប្រសិនបើព័ត៌មាននេះ មានលក្ខណៈ រសើប ឬ ត្រូវរក្សាការសម្ងាត់។

៥៨. ភាគីនានា ត្រូវទទួលបានពេលវេលាសមស្រប ដើម្បីផ្ញើឯកសារជាលាយលក្ខណ៍អក្សរ បង្ហាញពីការឆ្លើយតបរបស់ខ្លួន អមជាមួយនឹងភស្តុតាងនានា ប្រសិនបើមាន ដែលជាទូទៅរយៈពេលនេះមិនត្រូវតិចជាង ៣០ ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានលទ្ធផលរកឃើញ និង អនុសាសន៍អំពីការដាក់ទោសទណ្ឌរួចមក។

៥៩. ភាគី ដែលដឹង ពាក់ព័ន្ធ ឬមានទំនាក់ទំនង ដូចដែលត្រូវបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១ ដល់ ៨២ ដែលអាចចូលរួម នឹងត្រូវទទួលបានសេចក្តីជូនដំណឹងដោយឡែក ហើយក៏នឹងទទួលបានឱកាសឆ្លើយតបដូចគ្នាដែរ។

៦០. ភាគីក៏អាចស្នើសុំឱកាស ដើម្បីបង្ហាញដោយផ្ទាល់មាត់ដល់ OAI ផងដែរ ដោយត្រូវផ្តល់នូវមូលហេតុជាក់លាក់សម្រាប់ការស្នើសុំបែបនេះ។

៦១. OAI ត្រូវធ្វើការវាយតម្លៃឡើងវិញលើករណីមួយ បន្ទាប់ពីបានទទួលការឆ្លើយតប ហើយអាចធ្វើការស៊ើបអង្កេតបន្ថែមទៀត និង/ឬ ស្នើសុំព័ត៌មានបន្ថែមពីភាគីដែលស្ថិតនៅក្រោមការស៊ើបអង្កេត។

៦២. នៅក្នុងករណីដែលភាគីមួយ ដែលត្រូវបាន OAI រកឃើញថា បានប្រព្រឹត្ត

ការបំពានសុចរិតភាព បដិសេធចំពោះលទ្ធផលរកឃើញនៃការស៊ើបអង្កេត ដែលធ្វើឡើងដោយ OAI ឬនៅពេលដែលពុំមានការឆ្លើយតបចំពោះលទ្ធផលរកឃើញទាំងនេះ OAI ត្រូវផ្តល់ឱ្យគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព (IOC) នូវរបាយការណ៍មួយ ដែលបង្ហាញពីការស៊ើបអង្កេតរបស់ខ្លួន រួមជាមួយនឹងឯកសារគាំទ្រពាក់ព័ន្ធទាំងអស់ រួមទាំងការឆ្លើយតបរបស់ភាគីចំពោះលទ្ធផលរកឃើញទាំងនេះផង ប្រសិនបើមាន។

## *សេចក្តីជូនដំណឹងអំពីទោសទណ្ឌដែលត្រូវបានស្នើឱ្យដាក់*

៦៣. នៅក្នុងករណីសមស្រប OAI អាចផ្ញើលិខិតស្តីពីលទ្ធផលរកឃើញ រួមជាមួយនឹងទណ្ឌកម្មដែលត្រូវបានស្នើឡើង។ ភាគីត្រូវមានពេលសមស្រប ដែលជាទូទៅមិនត្រូវតិចជាង ៣០ ថ្ងៃប្រតិទិន ចាប់គិតពីកាលបរិច្ឆេទ ដែលបង្ហាញនៅក្នុងលិខិតស្តីពីលទ្ធផលរកឃើញនេះ សម្រាប់ធ្វើការឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ និងទណ្ឌកម្មដែលស្នើឡើង។

៦៤. នៅពេលដែលភាគីមិនបដិសេធ ហើយទទួលយកលទ្ធផលរកឃើញទាំងនេះ និងទណ្ឌកម្មដែលត្រូវបានស្នើឡើង ភាគីត្រូវបញ្ជាក់ពីការទទួលយកលទ្ធផលរកឃើញ និងទណ្ឌកម្មដែលស្នើឡើង មិនឱ្យហួសពីកាលបរិច្ឆេទដែលត្រូវបានបង្ហាញនៅក្នុងលិខិតបញ្ជាក់ពីលទ្ធផលរកឃើញនេះ។ តាមរយៈការបញ្ជាក់បែបនេះ ភាគីនេះក៏យល់ព្រមផងដែរថានឹងមិនប្តឹងឧទ្ធរណ៍លើទណ្ឌកម្មដែលស្នើឡើងនេះ និងរយៈពេលនៃការដាក់ទណ្ឌកម្មនេះឡើយ។ ទណ្ឌកម្មនេះ ត្រូវចូលជាធរមាន ចាប់ពីកាលបរិច្ឆេទនៃការទទួលបានការបញ្ជាក់ពី OAI ដរាបណាការបញ្ជាក់នេះ ត្រូវបានទទួលនៅក្នុងរយៈពេលដែលត្រូវបានបង្ហាញ។

៦៥. នៅក្នុងករណីដែលភាគីបដិសេធចំពោះលទ្ធផលរកឃើញ ឬទណ្ឌកម្មដែលត្រូវបានស្នើឡើង OAI ត្រូវបញ្ជូនករណីនេះទៅកាន់ IOC ស្របតាមកថាខណ្ឌទី ៦២។

### *ការខកខានមិនបានទទួលការជូនដំណឹង/ការឆ្លើយតប*

៦៦. ប្រសិនបើភាគីមួយបដិសេធមិនទទួលយកសេចក្ដីជូនដំណឹងពី OAI ឬទទួលបានសេចក្ដីជូនដំណឹងដែរ ប៉ុន្តែខកខានមិនឆ្លើយតប OAI ត្រូវទាញសេចក្ដីសន្និដ្ឋានអវិជ្ជមានពីការបដិសេធ ឬការខកខានបែបនេះ ហើយការខកខាន ឬការបដិសេធបែបនេះ ត្រូវចាត់ទុកថាជាស្ថានទំងន់ទោស។ IOC ឬ OAI អាចចាត់ទុកការខកខានរបស់ភាគីក្នុងការឆ្លើយតបនេះថា ជាមូលហេតុ សម្រាប់ធ្វើការផ្សព្វផ្សាយអំពីទណ្ឌកម្មនេះ ប្រសិនបើទណ្ឌកម្មនេះ ត្រូវបានដាក់ ដោយមិនគិតថា វាគឺជាទណ្ឌកម្មលើកដំបូងរបស់ភាគីនេះ និងអាចនាំឱ្យមានការហាមឃាត់ឱ្យគ្នាទៅវិញទៅមក។

## សកម្មភាពកែតម្រូវ

### *រដ្ឋាភិបាល*

៦៧. ប្រសិនបើលទ្ធផលរកឃើញបង្ហាញថា មន្ត្រីណាម្នាក់របស់រដ្ឋាភិបាលបានប្រព្រឹត្ត ឬពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តល្មើសទៅនឹងសុចរិតភាពមួយ OAI នឹងរាយការណ៍ពីលទ្ធផលរកឃើញនេះ ទៅកាន់គណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ OAI នឹងធ្វើការងារជាមួយគណៈគ្រប់គ្រង និងនាយកដ្ឋានប្រតិបត្តិការ ដើម្បីធ្វើការវាយតម្លៃលើវិធី ដែលធនាគារ-

អភិវឌ្ឍន៍អាស៊ីអាចធ្វើការឆ្លើយតប ស្របទៅតាមគោលនយោបាយប្រឆាំងអំពើពុករលួយ និងវិធាន គោលនយោបាយ និងនីតិវិធីដទៃទៀត។

### *បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី*

៦៨. ប្រសិនបើលទ្ធផលរកឃើញបង្ហាញថា បុគ្គលិកណាម្នាក់របស់ធនាគារ-អភិវឌ្ឍន៍អាស៊ីបានប្រព្រឹត្តល្មើសទៅនឹងសុចរិតភាពអ្វីមួយ ឬបានប្រព្រឹត្តអំពើមិនត្រឹមត្រូវផ្សេងទៀត ហើយ OAI សន្និដ្ឋានថា BPMSD គួរពិចារណាដាក់វិធានការវិន័យ ទៅតាមបញ្ជារដ្ឋបាល ២.០៤ OAI ត្រូវរាយការណ៍ពីលទ្ធផលរកឃើញរបស់ខ្លួនទៅកាន់ BPMSD។ BPMSD ត្រូវទទួលខុសត្រូវតែឯកឯង នៅក្នុងដំណើរការដាក់វិន័យនេះ ទៅតាមបញ្ជារដ្ឋបាល ២.០៤ បើទោះបីជា OAI អាចទទួលបានការពិគ្រោះយោបល់ និងការគាំទ្រដល់ BPMSD ពេញមួយដំណើរការដាក់វិន័យនេះក៏ដោយ។

### *គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព*

៦៩. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព មានសមាជិក ដែលមានសិទ្ធិបោះឆ្នោតចំនួន ៣ នាក់ ដែលក្នុងនោះសមាជិកម្នាក់ត្រូវជាអ្នកមកពីខាងក្រៅ ដែលមិនមែនជាបុគ្គលិករបស់ ADB។ ប្រធាន OAI ត្រូវដាក់ឈ្មោះ ហើយប្រធានធនាគារត្រូវតែងតាំងសមាជិករបស់គណៈកម្មាធិការនេះ ចេញពីបុគ្គលិកជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបំពេញការងារក្នុងរយៈពេលកំណត់មួយ[22]។ នាយក OAI ឬបុគ្គលិកដទៃទៀត ទៅតាម

22 ជាធម្មតា អាណត្តិនេះមានរយៈពេល ២៤ ខែ ប៉ុន្តែប្រធាន OAI និង/ឬប្រធានធនាគារ អាចកំណត់ពីរយៈពេលផ្សេងពីនេះ។

ការសម្រេចរបស់ប្រធានធនាគារ ត្រូវបំពេញនាទីជាលេខាធិការដ្ឋាន (មិនអាចបោះឆ្នោតបាន) សម្រាប់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ហើយត្រូវធានាយ៉ាងណាឱ្យសមាជិក ដែលត្រូវបានជ្រើសរើសសម្រាប់កិច្ចប្រជុំនីមួយៗ ពុំមានទំនាស់ផលប្រយោជន៍ នៅពេលចូលរួមនៅក្នុងការពិភាក្សា និងការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព។ បុគ្គលិក រាប់បញ្ចូលទាំងតំណាងមកពីនាយកដ្ឋាន/ការិយាល័យដទៃទៀត ដែលជំនាញឯកទេសរបស់ពួកគេមានភាពពាក់ព័ន្ធទៅនឹងករណី ដែលកំពុងស្ថិតក្រោមការពិចារណា អាចត្រូវអញ្ជើញឱ្យផ្តល់ដំបូន្មានដល់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព។ ការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន ប៉ុន្តែត្រូវរាប់បញ្ចូលសម្លេងឆ្នោតរបស់សមាជិករបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ដែលមកពីខាងក្រៅធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ នៅក្នុងករណីដែលសម្លេងរបស់សមាជិកខាងក្រៅ មិនមែនជាផ្នែកមួយនៃការសម្រេចចិត្តដោយសម្លេងភាគច្រើន លេខាធិការដ្ឋានត្រូវរៀបចំឱ្យមានជាកិច្ចប្រជុំថ្មីមួយ ដោយមានការចូលរួមពីសមាជិកទាំង ៣ រូប ដែលបានពិភាក្សាពីករណីនេះតាំងពីដំបូង បូករួមទាំងសមាជិកខាងក្នុងម្នាក់ និងសមាជិកខាងក្រៅម្នាក់ទៀត។ នៅក្នុងកិច្ចប្រជុំទី ២ របស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ដើម្បីពិភាក្សាអំពីករណីនេះ ការសម្រេចចិត្តត្រូវធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន។

៧០. ការបង្ហាញព័ត៌មានពីទំនាស់ផលប្រយោជន៍ ត្រូវធ្វើឡើងចំពោះគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព តាមរយៈលេខាធិការដ្ឋាននេះ។ សមាជិក ឬទីប្រឹក្សារបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព មិនត្រូវចូលរួម

នៅក្នុងការពិភាក្សា ឬការសម្រេចចិត្តណា ដែលពាក់ព័ន្ធនឹងបញ្ហាដែលខ្លួនមានទំនាស់ផលប្រយោជន៍ឡើយ។ ប្រសិនបើមានការជំទាស់ថាតើមានទំនាស់ផលប្រយោជន៍ដែរឬអត់ សមាជិកដទៃទៀតរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវធ្វើការសម្រេចចិត្ត។ ការដកខ្លួនចេញ និងការសម្រេចចិត្តអំពីទំនាស់ផលប្រយោជន៍ នឹងត្រូវចងក្រងទុកជាឯកសារលាយលក្ខណ៍អក្សរ ដោយលេខាធិការដ្ឋាន។

៧១. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ត្រូវកំណត់ថាតើមានមូលដ្ឋានសម្រាប់ចាត់វិធានការកែតម្រូវដែរឬទេ ដោយផ្អែកទៅតាមភស្តុតាងនានា របាយការណ៍របស់ OAI និងព័ត៌មានផ្សេងទៀត ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពអាចស្នើសុំ ឬ បង្ហាញជូន ដើម្បីបង្ហាញថា ភាគីដែលស្ថិតក្រោមការស៊ើបអង្កេត ពិតជាបានប្រព្រឹត្តល្មើសទៅនឹងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមែន។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព[23] អាចផ្ដល់នូវអនុសាសន៍ពាក់ព័ន្ធនឹងករណីដែលគណៈកម្មាធិការនេះ បានធ្វើការពិចារណា ហើយអាចធ្វើការពិចារណាថាតើត្រូវផ្សព្វផ្សាយជាសាធារណៈអំពីឈ្មោះក្រុមហ៊ុន ឬ បុគ្គលដែលត្រូវបានហាមឃាត់ទៅតាមកថាខណ្ឌទី ១១០-១១៣ ដែរឬទេ នៅក្នុងករណីលើកលែងមួយចំនួន។

### *ការផ្អាកការងារជាបណ្ដោះអាសន្ន*

៧២. នៅពេលណាក៏ដោយ នៅក្នុងកំឡុងពេលធ្វើការស៊ើបអង្កេតនេះ ដែលរកឃើញថា OAI មានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់លទ្ធផលរក

23 OAI ត្រូវបញ្ជូនអនុសាសន៍របស់ IOC ទៅភាគីពាក់ព័ន្ធ។

ឃើញនៃការបំពានសុចរិតភាពប្រឆាំងនឹងភាគីណាមួយ ហើយមានលទ្ធភាពខ្ពស់ដែលថា ការស៊ើបអង្កេតនេះនឹងបញ្ចប់ទៅក្នុងរយៈពេលយូរបំផុត ១ ឆ្នាំ OAI អាចបង្ហាញទៅកាន់ IOC នូវសំណើសុំផ្អាកការងារជាបណ្តោះអាសន្នរបស់ភាគីនេះសិន ក្នុងករណីដែលពុំមានការបដិសេធ។ សំណើនេះ ត្រូវមានសរសេរបញ្ចូលនូវសេចក្តីពិពណ៌នាអំពីវឌ្ឍនភាពបច្ចុប្បន្ននៃការស៊ើបអង្កេត ដែលកំពុងធ្វើបន្ត រួមនឹងភស្តុតាងនានា ដែលត្រូវធ្វើការប្រមូល រួមជាមួយនឹងការប៉ាន់ប្រមាណពីពេលវេលា ដែលចាំបាច់ ដើម្បីបញ្ចប់ការស៊ើបអង្កេតនេះ។

៧៣. ស្រដៀងគ្នានេះដែរ នៅក្នុងករណីដែលភាគីមួយត្រូវបានផ្អាកការងារជាបណ្តោះអាសន្ន ដោយស្ថាប័នចូលរួម ហើយប្រសិនបើ OAI រកឃើញថាការបន្តភាពស្របច្បាប់របស់ភាគីនេះអាចជាហានិភ័យធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ឬជាហានិភ័យធ្វើឱ្យមានការបំពានលើសុចរិតភាពបន្តទៀត រហូតដល់ពេលដែលភាគីនេះត្រូវបានហាមឃាត់ និងក្រោយពេលដែលបានពិគ្រោះយោបល់ជាមួយនឹងស្ថាប័នចូលរួម ដែលបានអនុវត្តការផ្អាកការងារជាបណ្តោះអាសន្នរួច បានសន្និដ្ឋានថា មានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់លទ្ធផលរកឃើញអំពីការបំពានសុចរិតភាពរបស់ភាគីនេះ ហើយមានលទ្ធភាពខ្ពស់ដែលថា ការស៊ើបអង្កេតនេះនឹងត្រូវបញ្ចប់នៅក្នុងរយៈពេលយូរបំផុត ១ឆ្នាំ OAI អាចបង្ហាញទៅកាន់ IOC នូវសំណើផ្អាកការងារបណ្តោះអាសន្ន ក្នុងករណីដែលគ្មានការជំទាស់ ដោយមានរៀបរាប់ដោយសង្ខេបអំពីមូលដ្ឋានដែលនាំឱ្យមានការសម្រេចចិត្តបែបនេះ ដោយស្ថាប័នចូលរួម ដើម្បីផ្អាកការងាររបស់ភាគីនេះជាបណ្តោះអាសន្ន។

៧៤. ដើម្បីធ្វើការពិចារណាលើការផ្អាកការងារជាបណ្តោះអាសន្ន IOC ត្រូវមានសមាជិកចំនួន ៣ នាក់ ប៉ុន្តែចាំបាច់ត្រូវតែមានសមាជិកពីខាងក្រៅម្នាក់។[24]

៧៥. ការផ្អាកការងារជាបណ្តោះអាសន្នត្រូវអនុញ្ញាតឱ្យមានសម្រាប់រយៈពេលរហូតដល់ ១៨០ ថ្ងៃ។ រយៈពេលផ្អាកការងារបណ្តោះអាសន្ន ដំបូងនេះអាចបន្តថែម ១៨០ ថ្ងៃទៀត ប្រសិនបើកាលៈទេសៈតម្រូវ និងមានការអនុញ្ញាតពី IOC។ ការផ្អាកការងារបណ្តោះអាសន្នមិនអាចបន្តលើសពី ៣៦០ ថ្ងៃឡើយ។

៧៦. ភាគីនេះត្រូវទទួលបានការជូនដំណឹងអំពីការផ្អាកការងារជាបណ្តោះអាសន្ន និងត្រូវទទួលបានព័ត៌មានមិនឱ្យចូលរួមនៅក្នុងសកម្មភាពនានា ដែលទទួលបានហិរញ្ញប្បទានពីគ្រប់គ្រងដោយ ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងរយៈពេលដែលមានការផ្អាកជាបណ្តោះអាសន្ននេះ។ គេមិនអាចប្តឹងឧទ្ធរណ៍អំពីការផ្អាកជាបណ្តោះអាសន្ននេះឡើយ។

៧៧. ភាគីមួយដែលត្រូវបានផ្អាកការងារជាបណ្តោះអាសន្ន ពុំមានសិទ្ធិចូលរួមនៅក្នុងសកម្មភាពនានា ដែលទទួលបានហិរញ្ញប្បទានពី ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីឡើយ។ ការព្យាយាមចូលរួមនៅក្នុងសកម្មភាពមួយ ដែលទទួលបានហិរញ្ញប្បទាន ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងកំឡុងពេលដែលមានការផ្អាកជាបណ្តោះអាសន្ននេះ នឹងនាំឱ្យមានការដាក់ទណ្ឌកម្មតិចបំផុត ៣ ឆ្នាំ ដែលអាចកាន់តែធ្ងន់ធ្ងរជាងមុន ឬ តិចជាងមុន ទៅតាមកថាខណ្ឌទី ៨៨ និង អាចត្រូវបានផ្សព្វផ្សាយលើ

24 នៅក្នុងករណីដែលចាំបាច់ អាចរៀបចំឱ្យមានកិច្ចប្រជុំតាមប្រព័ន្ធអេឡិចត្រូនិចរបស់ IOC បានដែរ។

គេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី អាចនាំឱ្យមាន ការហាមឃាត់ឱ្យគ្នាទៅវិញទៅមក។

៧៨. ប្រសិនបើភាគីដែលត្រូវបានផ្អាកការងារជាបណ្តោះអាសន្ន ត្រូវបានដាក់ទណ្ឌកម្មនៅពេលក្រោយមក ទណ្ឌកម្មនោះត្រូវបញ្ចូលរយៈពេលផ្អាកការងារបណ្តោះអាសន្នផងដែរ។

### *ការដាក់ទណ្ឌកម្ម*

៧៩. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចធ្វើការកំណត់ថា តើភាគីមួយ នឹងពុំមានលក្ខណៈសម្បត្តិសមស្រប ដើម្បីចូលរួមនៅក្នុងសកម្មភាពដែលទទួលបានហិរញ្ញប្បទាន ចាត់ចែង ឬ គ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ីដែរឬអត់ ៖

(i) ការហាមឃាត់៖ ការហាមឃាត់ឆ្លុះបញ្ចាំងពីការសម្រេចចិត្តរដ្ឋបាលថា នឹងមិនមានការធ្វើធុរកិច្ច ជាមួយនឹងភាគី ដែលធនាគារអភិវឌ្ឍន៍អាស៊ី មិនបានចាត់ទុកថាបានបំពេញទៅតាមស្តង់ដាក្រមសីលធម៌កម្រិតខ្ពស់បំផុត។ ការហាមឃាត់នេះ អាចមិនប៉ះពាល់ដល់កាតព្វកិច្ចក្រោមកិច្ចសន្យា ដែលមានស្រាប់ឡើយ ហើយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចផ្តល់ជាអនុសាសន៍ឱ្យកែសម្រួលកាតព្វកិច្ចក្រោមកិច្ចសន្យា ។[25]

25 សម្រាប់កិច្ចសន្យាផ្សេងៗពីគ្នា សូមមើលកថាខណ្ឌទី ៩២។

ការហាមឃាត់ ដែលមិនសំដៅលើការហាមឃាត់ជារៀងរហូត ត្រូវមានរយៈពេលកំណត់ជាអប្បបរមា។

(ii) ការហាមឃាត់ ជាមួយនឹងការទទួលស្គាល់ឡើងវិញដោយមានលក្ខខណ្ឌ៖ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចចិត្តថាគួរហាមឃាត់ភាគីណាមួយ ប៉ុន្តែត្រូវកំណត់លក្ខខណ្ឌជាក់លាក់ដែលអាចជួយកាត់បន្ថយរយៈពេលហាមឃាត់ ប្រសិនបើភាគីអាចបំពេញទៅតាមលក្ខខណ្ឌទាំងនោះបាន។ លក្ខខណ្ឌទាំងនេះ អាចមានដូចជា ៖ (i) ការកែលំអសុចរិតភាព និង/ឬការត្រួតពិនិត្យរបស់ក្រុមហ៊ុន ឬការអនុវត្តកម្មវិធីអនុលោមរបស់ក្រុមហ៊ុន, (ii) ចាត់វិធានការ ដើម្បីដាក់វិន័យ/បញ្ឈប់ការងាររបស់អ្នកទទួលខុសត្រូវលើការប្រព្រឹត្តបំពានសុចរិតភាព, (iii) កែលំអគ្រោះថ្នាក់ ដែលបង្កឡើងដោយការប្រព្រឹត្តបំពានសុចរិតភាព ដូចជាការកែតម្រូវ ឬសងត្រលប់ទៅវិញជាដើម។

(iii) ការមិនហាមឃាត់ដោយមានលក្ខខណ្ឌ៖ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចចិត្តថា មិនចាំបាច់មានការហាមឃាត់ដល់ភាគីមួយឡើយ ប្រសិនបើវិធានការមួយចំនួន ត្រូវបានអនុវត្តដោយភាគីនោះ។ នៅក្នុងករណីបែបនេះ ភាគីដែលទទួលទោសទណ្ឌមិនត្រូវបានហាមឃាត់ឡើយ ប៉ុន្តែចាំបាច់ត្រូវអនុលោមទៅតាមលក្ខខណ្ឌ ដែលកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ក្នុងរយៈពេលមួយកំណត់។ ប្រសិនបើភាគីដែលទទួលទោសទណ្ឌខកខានមិនបានបង្ហាញពីការអនុលោមទៅតាមលក្ខខណ្ឌទាំងនេះ នៅក្នុងរយៈពេលដែលបានកំណត់នោះទេ នោះការហាមឃាត់

នឹងចូលជាធរមានដោយស្វ័យប្រវត្តិ ក្នុងរយៈពេលដែលកំណត់ដោយគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI នៅពេលមានការសម្រេចចិត្តអំពីការមិនហាមឃាត់ដោយមានលក្ខខណ្ឌ។

៨០. ដើម្បីបង្ការមិនឱ្យមានការគេចវេសយករួចខ្លួន ជាទូទៅ ទណ្ឌកម្មនានានឹងត្រូវអនុវត្តចំពោះគ្រប់ស្ថាប័នទាំងអស់ ដែលគ្រប់គ្រងលើ ឬគ្រប់គ្រងដោយភាគី រួមទាំងស្ថាប័ន ដែលភាគីអាចមានប្រយោជន៍ ឬមានការគ្រប់គ្រងលើនាពេលអនាគតផងដែរ[26]។

៨១. នៅក្នុងករណី ដែលពាក់ព័ន្ធនឹងភាគីច្រើនរួមបញ្ចូលជាក្រុមមួយ ដូចជាការរួមហ៊ុន ជាដើម គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI នឹងដាក់ទោសទណ្ឌលើភាគី ដែលប្រព្រឹត្តបំពានសុចរិតភាព[27]។

៨២. គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចថា គួរដាក់ទោសទណ្ឌលើភាគីដែលពាក់ព័ន្ធ ឬលើអ្នកទទួលខុសត្រូវចម្បង (ដូចជាម្ចាស់ ប្រធាន មន្ត្រី ឬអ្នកមានភាគហ៊ុនសំខាន់ៗ) របស់ក្រុមហ៊ុនមួយ និង/ឬភាគីដែលពាក់ព័ន្ធដទៃទៀតប្រសិនបើមានការបញ្ជាក់ច្បាស់លាស់ បើទោះបីជាភាគីដែលពាក់ព័ន្ធមួយ មិនបានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការប្រព្រឹត្តបំពាននេះក៏ដោយ។ ប្រសិនបើដឹង ត្រូវមានបញ្ជាក់ឈ្មោះភាគីពាក់ព័ន្ធនៅក្នុងទណ្ឌកម្ម ហើយអាចរួមមានអ្នកដែលមាន ៖

26 ក្នុងការកំណត់ប្រយោជន៍ ឬ ការគ្រប់គ្រង OAI នឹងពិចារណាទៅលើកម្រិតនៃការពាក់ព័ន្ធ គម្លាតនៃអង្គភាពដែលត្រូវបានដាក់ទោសទណ្ឌ និង ភាពស្រដៀងគ្នានៃសកម្មភាពធុរកិច្ច ឬ ប្រតិបត្តិការជាមួយភាគីដែលត្រូវបានដាក់ទណ្ឌកម្ម។

27 OAI នឹងពិចារណាទៅលើកម្រិតនៃការចូលរួម និងកម្រិតនៃគណនេយ្យភាព ដែលអាចត្រូវបានកំណត់សម្រាប់ភាគីនីមួយៗនៅក្នុងការពាក់ព័ន្ធ។

(i) ទំនាក់ទំនងគ្រួសារ។

(ii) លទ្ធភាពលើការគ្រប់គ្រង ឬមានឥទ្ធិពលលើភាគីនេះ ដោយផ្ទាល់ ឬដោយប្រយោល។

(iii) មានកម្មសិទ្ធិ គ្រប់គ្រង ឬកាន់កាប់ជារួម ឬពាក់ព័ន្ធ ដែលមិនចាំបាច់ពាក់ព័ន្ធជាមួយនឹងកម្មសិទ្ធិ ឬសិទ្ធិ ក្នុងភាគរយណាមួយ។

(iv) កិច្ចព្រមព្រៀងជាមួយភាគីមួយទៀត ឬ ការពឹងអាស្រ័យលើភាគីមួយទៀត។

៨៣. នៅក្នុងការកំណត់ពីទោសទណ្ឌលើភាគីដែលពាក់ព័ន្ធ ឬអ្នកទទួលខុសត្រូវចម្បង គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវពិចារណាលើកត្តាខាងក្រោម ក្នុងចំណោមកត្តាផ្សេងទៀត ៖

(ក) ការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់អង្គភាព។

(ខ) ថាតើភាគីដែលពាក់ព័ន្ធ បានចូលរួម ឬមានឥទ្ធិពលធ្វើឱ្យមានការប្រព្រឹត្តបំពានសុចរិតភាពដែរឬទេ ឬថាតើភាគីពាក់ព័ន្ធ គឺជាអ្នកទទួលផលគោលដៅនៃការប្រព្រឹត្តបំពាននេះដែរឬទេ។

(គ) លទ្ធភាព ដែលភាគីស្ថិតនៅក្រោមការស៊ើបអង្កេត អាចចៀសវាងការដាក់ទោសទណ្ឌ តាមរយៈភាគីពាក់ព័ន្ធ ដោយធ្វើការពិចារណាអំពីឥទ្ធិពល ដែលភាគីស្ថិតនៅក្រោមការស៊ើបអង្កេត មានមកលើភាគីពាក់ព័ន្ធ និងថាតើភាគីស្ថិតនៅក្រោមការស៊ើបអង្កេតនេះអាចទទួលបានប្រយោជន៍អ្វី តាមរយៈភាគីពាក់ព័ន្ធ ដែរឬទេ។

៨៤. នៅពេលដែលសមស្រប គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចធ្វើការសម្រេចចិត្តមិនដាក់ទោសទណ្ឌលើភាគី ដែលសហការនៅក្នុងការស៊ើបអង្កេតរបស់ OAI។

៨៥. ដើម្បីលើកទឹកចិត្តភាគីឱ្យប្រាប់ OAI ភ្លាមៗអំពីការរំលោភបំពាននានាទៅលើសុចរិតភាព ដែលពួកគេពាក់ព័ន្ធ ឬ បាននិងកំពុងមានការពាក់ព័ន្ធដោយចេតនា ឬ អចេតនាក្តី OAI អាចផ្តល់ជាអនុសាសន៍ឱ្យមានការលើកលែង ឬបន្ធូរបន្ថយទណ្ឌកម្មលើភាគីណាមួយ ដែលបង្ហាញដោយស្មោះត្រង់អំពីការរំលោភបំពានទៅលើសុចរិតភាពមួយ និង សហការពេញលេញជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី។ ចំណុចនេះត្រូវយកមកអនុវត្ត ប្រសិនបើមានលក្ខខណ្ឌដូចខាងក្រោម ៖

i) ភាគីបានឈប់ប្រព្រឹត្តអំពើរំលោភបំពានទៅលើសុចរិតភាព។

ii) ភាគីបានផ្តល់ និង ត្រូវបានរំពឹងថានឹងបន្តផ្តល់ការបង្ហាញដោយពេញលេញ និងគ្រប់ជ្រុងជ្រោយ អំពីការរំលោភបំពាននានាទៅលើសុចរិតភាព ដែលភាគីមានការពាក់ព័ន្ធ ឬ បាននិងកំពុងមានការពាក់ព័ន្ធ។

iii) ការបង្ហាញត្រូវបានធ្វើឡើងទាន់ពេលវេលា និង ឆាប់បំផុតទៅតាមការដែលអាចធ្វើបានក្រោយពេល ដែលភាគីបានរកឃើញអំពីការរំលោភបំពានទៅលើសុចរិតភាព។

iv) ភាគីមិនស្ថិតក្រោមការស៊ើបអង្កេតសកម្ម ដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី ឬ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ធនាគារអភិវឌ្ឍន៍ពហុភាគី ឬ អង្គការទ្វេភាគី និង

v) ភាគីអនុវត្តស្របតាមលក្ខខណ្ឌដែលកំណត់ដោយ OAI សម្រាប់ការលើកលែង ឬ ការបន្ធូរបន្ថយ ទណ្ឌកម្ម។

ស្របតាមនីតិវិធីដែលបានបង្កើតឡើង ធនាគារអភិវឌ្ឍន៍អាស៊ី រក្សាសិទ្ធិកំណត់ដាក់ទណ្ឌកម្ម និង វិធានការ កែតម្រូវដទៃទៀតទៅលើភាគី ប្រសិនបើនៅពេលណាមួយ ក្រោយមក ធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា ភាគីនោះបាន ៖

ក) បន្ត ឬ ប្រព្រឹត្តអំពើរំលោភបំពានសុចរិតភាពដទៃទៀត។

ខ) ផ្ដល់ព័ត៌មានមិនគ្រប់ជ្រុងជ្រោយអំពីការរំលោភបំពានសុចរិតភាពដែលបានបង្ហាញ។

គ) មិនបានបង្ហាញប្រាប់ OAI ស្របតាមកថាខណ្ឌ ៨៥ (iii) ខាងលើ។

ឃ) ក្លាយជាកម្មវត្ថុនៃការស៊ើបអង្កេតមួយដ៏សកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ ស្ថាប័នហិរញ្ញវត្ថុ អន្តរជាតិដទៃទៀត នៅពេលធ្វើការបង្ហាញ ឬ

ង) មិនបានអនុវត្តស្របតាមលក្ខខណ្ឌដែលកំណត់ដោយ OAI សម្រាប់ការលើកលែង ឬ ការបន្ធូរបន្ថយទណ្ឌកម្ម។

### *ទោសទណ្ឌដទៃទៀត*

៨៦. ទោសទណ្ឌដទៃទៀត ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចសម្រេចឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ដាក់រួមមាន ៖

(i) ការព្រមាន៖ ការព្រមាន គឺជាការបន្ទោសដល់សកម្មភាពរបស់ភាគីមួយ និងការជូនដំណឹងថា ការប្រព្រឹត្តបំពានលើកក្រោយ នឹងទទួល

រងការដាក់ទោសខ្លាំងជាងនេះ។ ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ គឺសមស្របសម្រាប់ករណីដែលមានការត្រួតពិនិត្យមិនគ្រប់គ្រាន់ណាមួយ ឬនៅក្នុងករណីដែលការប្រព្រឹត្តបំពានសុចរិតភាព ឬ តួនាទីរបស់ភាគីមានត្រឹមតែតិចតួចប៉ុណ្ណោះនៅក្នុងករណីប្រព្រឹត្តបំពាននេះ។

(ii) ការទារឱ្យសងវិញ និង/ឬការកែតម្រូវ ៖ ការទាញឱ្យសងវិញ និងសកម្មភាពកែតម្រូវហិរញ្ញវត្ថុដទៃទៀត អាចត្រូវបានលើកជាអនុសាសន៍ ឬ ដាក់ដោយឯករាជ្យ ឬ រួមជាមួយនឹងទណ្ឌកម្មដទៃទៀត។

(iii) ការប្រុងប្រយ័ត្ន ៖ ការប្រុងប្រយ័ត្នត្រូវបានចេញ នៅពេលដែលភាគីមួយបានប្រព្រឹត្តអំពើឆ្គាំឆ្គង ដែលមិនទាន់ដល់កម្រិតជាការបំពានសុចរិតភាព (ឧ. ការធ្វេសប្រហែសជាធម្មតា)។

៨៧. ការព្រមាន ការទូទាត់សងវិញ ការកែតម្រូវ ឬការប្រុងប្រយ័ត្ន មិនប៉ះពាល់ដល់លក្ខណៈសមស្របរបស់ភាគីមួយ ដើម្បីចូលរួមនៅក្នុងសកម្មភាពនានាដែលទទួលហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ឬ គ្រប់គ្រង ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីឡើយ។

## រយៈពេលនៃការហាមឃាត់

៨៨. រយៈពេលគោលសម្រាប់ការហាមឃាត់ នៅក្នុងករណីប្រព្រឹត្តបំពានសុចរិតភាព ត្រូវបានកំណត់ ៣ ឆ្នាំ។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចកំណត់ពីរយៈពេលហាមឃាត់ច្រើនជាង ឬ តិចជាងនេះ អាស្រ័យទៅតាមកាលៈទេសៈរបស់ករណីនីមួយៗ។ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវពិចារណាលើកត្តាខាងក្រោម ក្នុងចំណោមកត្តា

ដទៃទៀត នៅពេលសម្រេចថា ត្រូវមានរយៈពេលតិច ឬច្រើន ៖

(i) គ្រោះថ្នាក់ពិតប្រាកដ ឬ គ្រោះថ្នាក់ដែលអាចកើតមានឡើង មិនថាចំពោះសុវត្ថិភាព/សុខុមាលភាពសាធារណៈ គម្រោង ឬ បញ្ហាដែលកំពុងស្ថិតនៅក្នុងការស៊ើបអង្កេត ឬផលប្រយោជន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី។

(ii) ភាពស្មុគស្មាញនៃការប្រព្រឹត្តបំពានសុចរិតភាព ដូចជា កម្រិតនៃការរៀបចំផែនការ, បច្ចេកទេសដែលបានប្រើប្រាស់, កម្រិតនៃការលាក់បាំង ចំនួន និងប្រភេទនៃបុគ្គល/អង្គការចាត់តាំងដែលពាក់ព័ន្ធ, រយៈពេលនៃការប្រព្រឹត្តបំពានសុចរិតភាព, របាយទីតាំងភូមិសាស្ត្រនៃការប្រព្រឹត្តបំពានសុចរិតភាព។

(iii) កម្រិតនៃការពាក់ព័ន្ធ ឬកម្រិតនៃការត្រួតពិនិត្យរបស់អ្នកគ្រប់គ្រង ឬរបស់អង្គការចាត់តាំងតែមួយ។

(iv) សារៈសំខាន់នៃតួនាទី ក្នុងការប្រព្រឹត្តបំពានសុចរិតភាព ឧទាហរណ៍ជាតួនាទីដឹកនាំ តួនាទីសំខាន់ ឬតួនាទីតូចតាច។

(v) ថាតើភាគីនេះបន្តប្រព្រឹត្តបំពានសុចរិតភាពដែរឬទេ បន្ទាប់ពីដឹងពីការស៊ើបអង្កេតរបស់ OAI ឬថាតើភាគីបានបញ្ឈប់ការប្រព្រឹត្តបំពាននេះដោយស្ម័គ្រចិត្ត។

(vi) កម្រិតនៃការសហការ ដែលបានបង្ហាញក្នុងកំឡុងពេលស៊ើបអង្កេត ឬ ការរារាំងដល់ការស៊ើបអង្កេត។

(vii) ថាតើភាគីធ្លាប់ត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីដាក់ទោសទណ្ឌដែរឬទេកន្លងមក ឬ ធ្លាប់ត្រូវបានស្ថាប័ន ឬ អង្គភាពមួយទៀតដាក់ទោសទណ្ឌ ឬ ហាមឃាត់ដែរឬទេ។

(viii) តើមានវិធានការកែតម្រូវណាមួយដែលធនាគារអភិវឌ្ឍន៍អាស៊ី ធ្លាប់បានអនុវត្តទៅលើភាគីកន្លងមក ដែរឬទេ។

(ix) សាវតាររបស់ភាគី ឬ របស់នាយកក្រុមហ៊ុន ឬ អ្នកទទួលខុសត្រូវចម្បងដទៃទៀតរបស់ក្រុមហ៊ុន។

(x) ការពាក់ព័ន្ធ និង តួនាទីរបស់មន្ត្រីសាធារណៈ ឬរបស់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការប្រព្រឹត្តបំពានសុចរិតភាពនេះ។

(xi) ការសងវិញ និងវិធានការនានា ដែលត្រូវបានអនុវត្ត ដើម្បីដោះស្រាយក្ដីកង្វល់ទាំងនេះ។

(xii) វត្តមាន ការបង្កើត ការកែលំអ ឬ ការអនុវត្តវិធានការអភិបាលកិច្ចផ្ទៃក្នុង ដើម្បីពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងដើម្បីបង្ការមិនឱ្យការប្រព្រឹត្តបំពានសុចរិតភាពនេះកើតឡើងម្ដងទៀត។

(xiii) ថាតើមានធនាគារអភិវឌ្ឍន៍ពហុភាគី ឬ អង្គការអន្តរជាតិផ្សេងទៀតបានហាមឃាត់ភាគីនេះដែរ ឬទេ។

៨៩. នៅក្នុងការកំណត់ថាតើត្រូវដាក់ការហាមឃាត់ក្នុងរយៈពេលច្រើន ឬ តិច គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI ត្រូវពិចារណាលើការកំណត់ ដូចខាងក្រោម ៖

(i) ការហាមឃាត់លើកដំបូង ដូចជា នៅក្នុងករណីដែលភាគីមួយ ធ្លាប់ទទួលបានការព្រមានពីមុនមក ៖

(ក) បុគ្គល៖ រហូតដល់មិនកំណត់។

(ខ) ក្រុមហ៊ុន៖ រហូតដល់ ៧ ឆ្នាំ។

(ii) ការហាមឃាត់លើកទីពីរ ៖

(ក) បុគ្គល៖ រហូតដល់មិនកំណត់។

(ខ) ក្រុមហ៊ុន៖ រហូតដល់ ១០ ឆ្នាំ។

(iii) ការហាមឃាត់ក្រោយៗទៀត ៖

(ក) បុគ្គល៖ រហូតដល់មិនកំណត់។

(ខ) ក្រុមហ៊ុន៖ រហូតដល់ ២០ ឆ្នាំ។

៩០. ដោយទទួលស្គាល់ថាកម្មសិទ្ធិ រចនាសម្ព័ន្ធស្ថាប័ន និង/ឬគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន អាចមានការផ្លាស់ប្ដូរនៅក្នុងរយៈពេលមួយ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងហាមឃាត់ក្រុមជារៀងរហូត តែនៅក្នុងករណីពិសេសតែប៉ុណ្ណោះ (ដូចជា ការប្រព្រឹត្តបំពានសុចរិតភាពម្ដងហើយម្ដងទៀត ការធ្វើឱ្យប៉ះពាល់ជាពិសេសដល់ប្រយោជន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម)។ ដោយសារតែបុគ្គលិកលក្ខណៈរបស់បុគ្គលទំនងជានឹងងាយផ្លាស់ប្ដូរ ធនាគារអភិវឌ្ឍន៍អាស៊ីអាចហាមឃាត់បុគ្គល ដែលប្រព្រឹត្តបំពានសុចរិតភាពដោយគ្មានកំណត់ពេល។

៩១. នៅពេលដែលភាគីមួយត្រូវបានគេរកឃើញថា ធ្លាប់ពាក់ព័ន្ធជាមួយនឹងករណីបំពានសុចរិតភាពច្រើនករណី ដែលត្រូវបានរកឃើញនៅពេល ឬប្រហែលជាពេលជាមួយគ្នា (ឧ. ការសមគំនិតគ្នា និងការផ្តល់ព័ត៌មានមិនត្រឹមត្រូវនៅក្នុងកំឡុងពេលដំណើរការលទ្ធកម្ម) អាចនៅក្នុងគម្រោងតែមួយ ឬ គម្រោងផ្សេងគ្នា ភាគីនេះអាចទទួលការដាក់ទណ្ឌកម្មសរុប ឬច្រើនក្នុងពេលជាមួយគ្នា។

៩២. ប្រសិនបើភាគីដែលទទួលរងការដាក់ទណ្ឌកម្មកំពុងមានកិច្ចសន្យា ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទណ្ឌកម្មនេះអាចមិនប៉ះពាល់ដល់កាតព្វកិច្ចសន្យាដែលមានស្រាប់ឡើយ។ ការបំពានកិច្ចសន្យាណាមួយត្រូវមានការគាំទ្រពី OAI ដើម្បីធានាយ៉ាងណាឱ្យការផ្លាស់ប្តូរកិច្ចសន្យាដែលពាក់ព័ន្ធជាមួយនឹងភាគីដែលទទួលរងទណ្ឌកម្មនេះ មិនមែនជាការព្យាយាមគេចវេសពីទណ្ឌកម្មនេះឡើយ។ នាយកដ្ឋានដែលធ្វើប្រតិបត្តិការ និង ភាគីដែលទទួលរងការដាក់ទណ្ឌកម្ម មានការទទួលខុសត្រូវធានាថា OAI ពុំមានការជំទាស់ទៅនឹងការផ្លាស់ប្តូរ ដែលត្រូវបានលើកស្នើនៅក្នុងកិច្ចសន្យាដែលកំពុងមានឡើយ។ ការដែលអង្គភាពទទួលរងការដាក់ទណ្ឌកម្ម មិនបានស្នើសុំការគាំទ្រ អាចនាំឱ្យមានការបន្តរយៈពេលហាមឃាត់។[28]

28 ភាគី ដែលទទួលរងការដាក់ទណ្ឌកម្ម ត្រូវធ្វើការពិភាក្សាអំពីសំណើផ្លាស់ប្តូរកិច្ចសន្យាជាមួយនឹងនាយកដ្ឋានប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង/ឬទីភ្នាក់ងារប្រតិបត្តិ/ អនុវត្ត ដើម្បីស្នើសុំការគាំទ្រពី OAI។

## ការបំពានទណ្ឌកម្ម

៩៣. ការព្យាយាម ឬ ការចូលរួមនៅក្នុងសកម្មភាពដែលទទួលបានហិរញ្ញប្បទាន ពី ឬ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងពេលដែលកំពុងត្រូវបានហាមឃាត់ ឬ ធ្វើការផ្លាស់ប្តូរកិច្ចសន្យា ដោយមិនមានការគាំទ្រពី OAI នឹងត្រូវចាត់ទុកថាជាការបំពានទណ្ឌកម្ម។ នៅក្នុងករណីបែបនេះធនាគារអភិវឌ្ឍន៍អាស៊ី នឹងបន្តរយៈពេលហាមឃាត់ទៀត ប្រសិនបើករណីនេះនៅតែបន្តកើតមាន ឬ កំណត់រយៈពេលហាមឃាត់បន្ថែម។ ទណ្ឌកម្មបន្ថែមនេះនឹងត្រូវបានដាក់រយៈពេលតិចបំផុត ៣ ឆ្នាំ ដែលអាចបង្កើន ឬ បន្ធូរបន្ថយ ស្របតាម កថាខណ្ឌ ៨៨-៨៩ ហើយនឹងត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការផ្សព្វផ្សាយ លើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី អាចនាំឱ្យមានការហាមឃាត់ឱ្យគ្នាទៅវិញទៅមក។

## សេចក្តីជូនដំណឹងអំពីការសម្រេចចិត្តអំពីវិធានការកែតម្រូវ

៩៤. OAI នឹងធ្វើការផ្សព្វផ្សាយអំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អំពីវិធានការកែតម្រូវ ដោយរាប់បញ្ចូលទាំងមូលដ្ឋាន និងលក្ខខណ្ឌផ្សេងៗនៃវិធានការបែបនេះ ទៅកាន់ភាគីដែលពាក់ព័ន្ធ រួមទាំងទីភ្នាក់ងារប្រតិបត្តិ ឬ ទីភ្នាក់ងារអនុវត្ត និងនាយកដ្ឋានពាក់ព័ន្ធទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ នៅក្នុងគ្រប់ករណីទាំងអស់ ដែលគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព បានសម្រេចចិត្តដាក់ទណ្ឌកម្មអ្វីមួយ OAI ត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីសិទ្ធិតវ៉ាស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបានដាក់ចេញនៅក្នុងគោលការណ៍

និងសេចក្តីណែនាំអំពីសុចរិតភាពទាំងនេះ។ នៅក្នុងករណីដែល OAI មិនអាចជូនដំណឹងដល់ភាគីមួយអំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពបាន OAI ត្រូវផ្សព្វផ្សាយជាសាធារណៈនូវការសម្រេចចិត្តនេះលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមនីតិវិធីដែលបង្ហាញខាងក្រោម។

៩៥. ដោយសហការជាមួយនឹងគណៈគ្រប់គ្រង និងនាយកដ្ឋាន/ការិយាល័យដែលពាក់ព័ន្ធ OAI ត្រូវធានាឱ្យមានការត្រួតពិនិត្យ ដើម្បីពង្រឹងការអនុវត្តវិធានការកែតម្រូវនេះ។

## ការប្តឹងឧទ្ធរណ៍

៩៦. ភាគីដែលត្រូវបានហាមឃាត់ដោយធនាគារអភិវឌ្ឍន៍អាស៊ីអាចប្តឹងឧទ្ធរណ៍ទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព មិនឱ្យលើសពី ៩០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់ OAI អំពីការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព។ ភាគីដែលទទួលរងទោសទណ្ឌទាំងឡាយណាដែល OAI មិនអាចជូនដំណឹងអំពីទោសទណ្ឌនេះបាន ដោយភាគីនោះមិនមែនជាអ្នកមានកំហុសធ្វើឱ្យពុំអាចជូនដំណឹងនេះបាន ប៉ុន្តែក្រោយមក ភាគីនេះដឹងពីទោសទណ្ឌនេះ ភាគីនេះអាចប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល៩០ថ្ងៃ ចាប់ពីពេលជូនដំណឹងទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ ទទួលបាន ឬ ដឹងអំពីទណ្ឌកម្ម។ ការប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយរៀបរាប់ឱ្យបានច្បាស់លាស់ អំពីមូលហេតុដែលខ្លួនស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការសម្រេចចិត្ត របស់គណៈកម្មាធិការ

ត្រួតពិនិត្យសុចរិតភាព ហើយត្រូវពន្យល់ទៅតាមការដែលអាចធ្វើទៅបាន អំពីមូលហេតុ ដែល OAI មិនអាចទាក់ទងភាគីបាន។

៩៧. ការហាមឃាត់ ដោយសារទណ្ឌកម្មដែលអាចទទួលយកបាន ស្របទៅតាមកថាខណ្ឌទី ៦៤ ឬ ការប្រព្រឹត្តបំពាននឹងទោសទណ្ឌ មិនអាចប្តឹងឧទ្ធរណ៍បានឡើយ ហើយការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI គឺជាការសម្រេចចិត្តស្ថាពរ។

៩៨. គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ត្រូវពិចារណាលើបណ្តឹងឧទ្ធរណ៍ដែលមានព័ត៌មានថ្មីៗ នៅក្នុងករណីដែល ៖

(i) ព័ត៌មាននេះមិនមាន ឬ មិនដឹង ឬ មិនអាចដឹងដោយសារមូលហេតុសមស្របចំពោះភាគី នៅពេលដែល OAI ព្យាយាមសុំការពន្យល់ពីភាគីហើយ

(ii) ព័ត៌មាននេះ មានភាពពាក់ព័ន្ធជាមួយករណី ហើយអាចមានភាពពាក់ព័ន្ធជាមួយនឹងការសម្រេចចិត្តអំពីការដាក់ទោសទណ្ឌ។

៩៩. គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ អាចកាត់បន្ថយ ឬ ដកចេញនូវទោសទណ្ឌ ដែលដាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ី បន្ទាប់ពីបានពិនិត្យពិចារណាលើបណ្តឹងឧទ្ធរណ៍រួចមក។ ជាជម្រើសវិធានការមួយទៀត គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌអាចតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ធ្វើការស៊ើបអង្កេតឡើងវិញលើករណីណាមួយ និងដាក់ពាក្យបណ្តឹងសារជាថ្មីទៅកាន់ IOC។ គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ត្រូវមានការចូលរួមពីអនុប្រធានធនាគារចំនួន ២ ឬ ៣ រូប

អាស្រ័យទៅតាមលក្ខណៈរបស់ករណី និងរយៈពេលនៃទោសទណ្ឌ[29]។ ប្រធានត្រូវតែងតាំងលេខាធិការដ្ឋានមួយនៃគណៈកម្មាធិការឧទ្ធរណ៍ ដែលមានសមាសភាពមកពីបុគ្គលិកជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី រៀងរាល់២ឆ្នាំម្តង។ លេខាធិការដ្ឋានត្រូវធានាថា សមាជិកគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ពុំមានទំនាស់ផលប្រយោជន៍ណាមួយនៅពេលពិចារណាអំពីបណ្តឹងឧទ្ធរណ៍។ អនុប្រធាន ដែលមានអាណត្តិការងារវែងជាងគេ គឺជាប្រធានគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនេះ។ ប្រធាន OAI ត្រូវតែងតាំងសមាជិករបស់គណៈកម្មាធិការនេះ ហើយត្រូវបំពេញតួនាទីជាទីប្រឹក្សាសម្រាប់គណៈកម្មាធិការនេះ។ អគ្គមេធាវីអាចមានវត្តមានជាទីប្រឹក្សា។ នៅក្នុងករណីដែលមិនមានភាពស្មុគស្មាញ លេខាធិការដ្ឋានអាចបញ្ជូនករណីបណ្តឹងឧទ្ធរណ៍នេះ ទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌ ផ្អែកទៅតាមមូលដ្ឋានគ្មានការជំទាស់។ នៅក្នុងករណីបែបនេះ គណៈកម្មាធិការនេះ ត្រូវមានការចូលរួមពីអនុប្រធានធនាគារចំនួន ២ រូប លុះត្រាតែមានសមាជិកម្នាក់ ក្នុងចំណោមសមាជិកពីរនាក់របស់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនេះ ស្នើសុំឱ្យមានការចូលរួមពីអនុប្រធានធនាគារទី ៣ នៅក្នុងការសម្រេចចិត្តអំពីបណ្តឹងឧទ្ធរណ៍នេះ។

១០០. គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌនឹងធ្វើការសម្រេចចិត្តរបស់ខ្លួន តែនៅពេលដែលមានការឯកភាពគ្នាជាឯកច្ឆ័ន្ទពីគ្រប់សមាជិកទាំងអស់។

29 ប្រសិនបើលក្ខណៈទោសទណ្ឌទាមទារឱ្យមានការចូលរួមពីអនុប្រធានធនាគារចំនួនបីនាក់ ហើយលេខាធិការដ្ឋានសម្រេចថា គេមិនអាចរៀបចំឱ្យមានកិច្ចប្រជុំពីអនុប្រធានធនាគារទាំងបីនាក់ ក្នុងរយៈពេលមួយសមស្របបាននោះទេ ប្រធានគណៈកម្មាធិការអាចតែងតាំងប្រធាន ឬអនុប្រធាននាយកដ្ឋាន ឬការិយាល័យណាមួយ ធ្វើជាសមាជិកទីបី របស់គណៈកម្មាធិការនេះ។

ប្រសិនបើប្រធានគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌសម្រេចចិត្តថា គណៈកម្មាធិការនេះ មិនអាចឈានដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទ ប្រធានគណៈកម្មាធិការត្រូវស្នើសុំឱ្យមានការចូលរួមពីប្រធានធនាគារ។ ប្រធានធនាគារត្រូវជួយដោះស្រាយការខ្វែងគំនិតគ្នានេះ ហើយត្រូវទុកលទ្ធភាពឱ្យគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌធ្វើការសម្រេចចិត្តរួមគ្នា ឬប្រសិនបើនៅតែមិនអាចសម្រេចចិត្តរួមគ្នាបានទៀត ប្រធានធនាគារត្រូវធ្វើការសម្រេចចិត្តចុងក្រោយ។

១០១. ការសម្រេចចិត្តរបស់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌអំពីបណ្ដឹងឧទ្ធរណ៍ណាមួយ និងការសម្រេចចិត្តរបស់គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព លើករណីដែលគណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌបញ្ជូនត្រលប់មកវិញ ត្រូវតែជាការសម្រេចចិត្តស្ថាពរ ចងកាតព្វកិច្ច និងមិនអាចប្ដឹងឧទ្ធរណ៍បន្តទៀតឡើយ។

## ការទទួលស្គាល់ឡើងវិញ

១០២. ភាគី ដែលត្រូវបានហាមឃាត់ មិនត្រូវបានទទួលស្គាល់ឡើងវិញដោយស្វ័យប្រវត្តិឡើយ បន្ទាប់ពីរយៈពេលហាមឃាត់អប្បបរមាបានផុតកំណត់។ ដើម្បីស្ដារឡើងវិញឱ្យមានលក្ខខណ្ឌសមស្រប ភាគីដែលត្រូវបានហាមឃាត់ ត្រូវស្វែងរកការទទួលស្គាល់ឡើងវិញ។ ក្រោយពេលទទួលបានសំណើសុំការទទួលស្គាល់ឡើងវិញ ធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈ OAI នឹងធ្វើការប៉ាន់ប្រមាណឡើងវិញទៅលើទណ្ឌកម្ម ដើម្បីកំណត់ថាតើ ត្រូវទទួលស្គាល់ភាគីឡើងវិញ ឬ បន្តរយៈពេលហាមឃាត់ (ឧ. ប្រសិនបើគេដឹងថា ភាគីបានចូលរួមនៅក្នុងអំពើរំលោភបំពានសុចរិត

ភាពណាមួយ ក្នុងអំឡុងពេលនៃរយៈពេលដាក់ទណ្ឌកម្ម) ស្របតាមនីតិវិធីស្តីពីការទទួលស្គាល់ឡើងវិញដែលមានគូសបញ្ជាក់ខាងក្រោម។

១០៣. ការស្នើសុំការទទួលស្គាល់ឡើងវិញត្រូវ ៖

(i) ធ្វើឡើងជាលាយលក្ខណ៍អក្សរ ផ្ញើទៅកាន់នាយក OAI។

(ii) លើកឡើងពីមូលហេតុនៃការដាក់ទោសទណ្ឌ និង

(iii) ផ្តល់នូវព័ត៌មានជាមូលដ្ឋាន សម្រាប់ឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការពិចារណាលើការទទួលស្គាល់ឡើងវិញ។

១០៤. OAI នឹងធ្វើការវាយតម្លៃលើភាពជឿជាក់នៃសំណើសុំការទទួលស្គាល់ឡើងវិញនេះ ហើយនឹងធ្វើការវាយតម្លៃមូលដ្ឋាន ដើម្បីទទួលស្គាល់ភាគីណាមួយឡើងវិញ។ កត្តាដែល OAI អាចយកមកធ្វើការពិចារណារួមមាន ៖

(i) ការអនុលោមទៅតាមលក្ខខណ្ឌ ដែលត្រូវបានដាក់អនុលោមទៅតាមកថាខណ្ឌ ៧៩ (ii)

(ii) មូលហេតុ នៃការដាក់ទោសទណ្ឌ

(iii) ការសងវិញ

(iv) ការផ្លាស់ប្តូរអ្នកគ្រប់គ្រង ឬកម្មសិទ្ធិរបស់ក្រុមហ៊ុន និងថាតើអ្នកទទួលខុសត្រូវចម្បងរបស់ក្រុមហ៊ុន នៅបានទទួលរងទោសទណ្ឌដែរឬទេ?

(v) យន្តការ ដែលអាចផ្ទៀងផ្ទាត់បាន ដើម្បីកែលំអអភិបាលកិច្ចរបស់ក្រុមហ៊ុន។

(vi) វិធានការផ្នែករដ្ឋបាល រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលភាគីដែលត្រូវបានហាមឃាត់បានផ្តួចផ្តើម ឡើងដើម្បីកែតម្រូវលើការប្រព្រឹត្តបំពានសុចរិតភាពរបស់ខ្លួន។

(vii) ព័ត៌មានផ្សេងទៀត ដែលបង្ហាញថា ភាគីនេះនៅតែពាក់ព័ន្ធនឹងការប្រព្រឹត្តបំពានសុចរិតភាព បន្ទាប់ពីទទួលទោសទណ្ឌពីធនាគារអភិវឌ្ឍន៍អាស៊ីរួមទាំងទោសទណ្ឌដែលដាក់ដោយស្ថាប័នផ្សេងទៀត។

(viii) លទ្ធផលនៃការស៊ើបអង្កេតរដ្ឋបាល ឬព្រហ្មទណ្ឌ។

១០៥. បន្ទាប់ពីបានបញ្ចប់ការពិនិត្យឡើងវិញ ឬ ការស៊ើបអង្កេតរបស់ខ្លួនរួច OAI ត្រូវកំណត់ថាតើត្រូវទទួលស្គាល់ភាគីមួយបានដែរឬទេ។ ប្រសិនបើ OAI សម្រេចថា មិនទទួលស្គាល់ភាគីមួយឡើងវិញទេនោះ OAI ត្រូវរៀបចំ របាយការណ៍មួយ សម្រាប់ដាក់ជូនគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ជាមួយនឹងអនុសាសន៍បែបនេះ។ គណៈកម្មាធិការត្រួតពិនិត្យ សុចរិតភាព អាចធ្វើការសម្រេចចិត្តទទួលស្គាល់ឡើងវិញនូវភាពសមស្របរបស់ភាគីនោះ ឬបន្តការដាក់ទោសទណ្ឌ សម្រាប់រយៈពេលអប្បបរមាមួយទៀត ដែលបន្ទាប់ពីរយៈពេលនេះ ភាគីនេះអាចស្នើសុំការទទួលស្គាល់ឡើងវិញម្តងទៀត។

១០៦. នៅក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ីហាមឃាត់ភាគីដែលពាក់ព័ន្ធអ្នកទទួលខុសត្រូវចម្បងរបស់ក្រុមហ៊ុន ឬ ភាគីដែលពាក់ព័ន្ធផ្សេងទៀត

ស្របជាមួយនឹងការដាក់ទោសទណ្ឌលើក្រុមហ៊ុន ដែលបានប្រព្រឹត្តល្មើសនឹងគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ការពិនិត្យឡើងវិញ និង អនុសាសន៍របស់ OAI និងការសម្រេចចិត្តលើសំណើសុំការទទួលស្គាល់ឡើងវិញ ក៏អាចលើកឡើងពីការផ្តល់ការទទួលស្គាល់ឡើងវិញដល់ភាគីទាំងនោះផងដែរ។

១០៧. OAI នឹងផ្សព្វផ្សាយការសម្រេចចិត្តរបស់ខ្លួនលើសំណើសុំការទទួលស្គាល់ឡើងវិញ ជាលាយលក្ខណ៍អក្សរ ដោយមានរៀបរាប់ពីមូលដ្ឋាននៃការសម្រេចចិត្តបន្តទោសទណ្ឌ សម្រាប់រយៈពេលអប្បបរមាមួយទៀត។ ប្រសិនបើគណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពសម្រេចបន្តទោសទណ្ឌ ក្នុងរយៈពេលអប្បបរមាមួយទៀត ភាគីអាចប្តឹងឧទ្ធរណ៍អំពីការសម្រេចចិត្តនេះទៅកាន់គណៈកម្មាធិការឧទ្ធរណ៍លើទោសទណ្ឌអនុលោមទៅតាមនីតិវិធីនៃបណ្តឹងឧទ្ធរណ៍។

១០៨. នៅក្នុងករណីលើកលែង OAI អាចវាយតម្លៃលើលក្ខណៈសម្បត្តិសម្រាប់ទទួលស្គាល់ភាគីមួយឡើងវិញ ឬ ដកភាគីនេះ (រួមទាំងភាគីដែលត្រូវបានហាមឃាត់ជារៀងរហូត) ចេញពីបញ្ជីភាគីហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ OAI អាចធ្វើបែបនេះ ដើម្បីបង្ការកុំឱ្យមានការដាក់ទោសទណ្ឌមិនត្រឹមត្រូវ ឬ ដើម្បីបង្ការកុំឱ្យបញ្ជីភាគីហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី មិនអាចប្រើប្រាស់បានទៀតតែប៉ុណ្ណោះ។

១០៩. ភាគីមួយ នឹងត្រូវទទួលស្គាល់ឡើងវិញ ប្រសិនបើភាគីនោះបានប្តឹងជំទាស់ការដាក់ទណ្ឌកម្មមួយដោយជោគជ័យ ឬ OAI កំណត់ថាមានការដាក់ទោសទណ្ឌមិនត្រឹមត្រូវ។

## ការបង្ហាញព័ត៌មានជាសាធារណៈ

១១០. បញ្ជីឈ្មោះភាគី ដែលហាមឃាត់ដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ជាលើកដំបូងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ លើកលែងតែដូចដែលត្រូវបានកំណត់ នៅក្នុងកថាខណ្ឌ ៦៦, ៧១, ១១២ និង ១១៣ ប៉ុន្តែបញ្ជីនេះ មិនមែនជាបញ្ជីលាក់ការសម្ងាត់ឡើយ ដោយសារតែ OAI អាចផ្តល់បញ្ជីឈ្មោះភាគីហាមឃាត់ ដោយធនាគារអភិវឌ្ឍន៍អាស៊ី ដល់ភាគីផ្សេងទៀតដែលចាំបាច់ត្រូវដឹង ដូចជា ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្ថាប័នអភិវឌ្ឍន៍ ពហុភាគីដទៃទៀត និង ទីភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ជាដើម។

១១១. OAI នឹងជូនដំណឹងដល់ភាគី ដែលត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីប្រកាសថាពុំមានលក្ខណៈសមស្របថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹង មិនផ្សព្វផ្សាយនូវឈ្មោះរបស់ពួកគេឡើយ ប៉ុន្តែការប៉ុនប៉ងរបស់ភាគីទាំងនោះ ដើម្បីចូលរួមនៅក្នុងសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ឬដែលត្រូវបានគ្រប់គ្រង ឬគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ខណៈពេលដែលភាគីនោះកំពុងមានភាពមិនស្រប នឹងធ្វើឱ្យមានការបន្តរយៈពេលទោសទណ្ឌ និងការផ្សព្វផ្សាយនូវឈ្មោះរបស់ភាគីទាំងនោះ លើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយភាគីនេះអាចទទួលបានការហាមឃាត់ពីស្ថាប័នដទៃទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តការហាមឃាត់ឱ្យគ្នាទៅវិញទៅមក។ OAI ក៏នឹងផ្សព្វផ្សាយនូវឈ្មោះភាគី ដែលត្រូវបានហាមឃាត់ទៅតាម

កថាខណ្ឌទី ៨៩ (ii) និង (iii) ផងដែរ។ ការផ្សព្វផ្សាយនេះមិនត្រូវធ្វើមុនពេលផុតកំណត់រយៈពេលប្តឹងឧទ្ធរណ៍ ឬ ការបដិសេធនៃបណ្តឹងប្រសិនបើមាន។

១១២. ប្រសិនបើភាគីនៃការសម្រេចចិត្តហាមឃាត់ មិនបានបញ្ជាក់ថា បានទទួលសេចក្តីជូនដំណឹងអំពីទណ្ឌកម្ម បើទោះបីជាភាគីនោះបានទទួលការជូនដំណឹងក៏ដោយ ហើយភាគីនោះបដិសេធមិនបានទទួលការជូនដំណឹង ឬ បានផ្លាស់ប្តូរទីតាំង ហើយរកមិនឃើញ បើទោះបីជា OAI បានខិតខំស្វែងរកក្នុងកម្រិតមួយសមស្រប គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាព ឬ OAI អាចឯកភាពលើការផ្សព្វផ្សាយពីព័ត៌មាននេះ រួមទាំងឈ្មោះរបស់ភាគីលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលអាចធ្វើឱ្យមានការហាមឃាត់ពីស្ថាប័នផ្សេងទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍ការសម្រេចចិត្តស្តីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក។

១១៣. នៅក្នុងករណីលើកលែង ដូចជា ករណីដែលមានការប្រព្រឹត្តបំពានសុចរិតភាពធ្ងន់ធ្ងរ គណៈកម្មាធិការត្រួតពិនិត្យសុចរិតភាពអាចសម្រេចផ្សព្វផ្សាយសាធារណៈអំពីទោសទណ្ឌនេះ បើទោះបីនេះគឺជាកាប្រព្រឹត្តល្មើសលើកដំបូងក៏ដោយ។

## ការហាមឃាត់ឱ្យគ្នាទៅវិញទៅមក

១១៤. នៅក្រោមកិច្ចព្រមព្រៀងស្តីពីការអនុវត្តការសម្រេចចិត្តស្តីពីការហាមឃាត់

ឱ្យគ្នាទៅវិញទៅមក ការសម្រេចចិត្តហាមឃាត់ ដោយស្ថាប័នមួយដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ មានភាពសមស្របគ្រប់គ្រាន់សម្រាប់ឱ្យស្ថាប័នដទៃទៀត ដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះដែរ ប្រសិនបើ ៖

(i) ការសម្រេចចិត្តនេះ មានមូលដ្ឋានទាំងស្រុង ឬ ផ្នែកខ្លះ លើលទ្ធផលរកឃើញអំពីការអនុវត្ត ដែលត្រូវទទួលរងទោសទណ្ឌ ដូចដែលបានកំណត់នៅក្រោមក្របខ័ណ្ឌរួមសម្រាប់ទប់ស្កាត់ និងបង្ក្រាបការគៃបន្លំ និងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៦។ ការអនុវត្តទាំងនេះ រួមមាន ការប្រព្រឹត្តអំពើពុករលួយ ការគៃបន្លំ ការបង្ខិតបង្ខំ និងការឃុបឃិតគ្នា ជាដើម។

(ii) ការសម្រេចចិត្តនេះ ត្រូវបានផ្សព្វផ្សាយដោយស្ថាប័នដែលដាក់ទោសទណ្ឌ។

(iii) រយៈពេលបឋមនៃការហាមឃាត់ មានលើសពី ១ ឆ្នាំ។

(iv) ការសម្រេចចិត្តនេះត្រូវបានធ្វើឡើង បន្ទាប់ពីកិច្ចព្រមព្រៀងជាមួយនឹងស្ថាប័នដាក់ទោសទណ្ឌបានចូលជាធរមាន។

(v) ការសម្រេចចិត្តដោយស្ថាប័នដាក់ទោសទណ្ឌ ត្រូវបានធ្វើឡើងក្នុងរង្វង់រយៈពេល ១០ ឆ្នាំ គិតចាប់ពីពេលមានការទទួលស្គាល់លើការអនុវត្ត ដែលត្រូវទទួលទោសទណ្ឌ និង

(vi) ការសម្រេចចិត្តដោយស្ថាប័នដាក់ទោសទណ្ឌ មិនត្រូវបានធ្វើឡើងដោយទទួលស្គាល់ពីការសម្រេចចិត្ត ដែលធ្វើឡើងនៅក្នុងវេទិកាជាតិ ឬ អន្តរជាតិដទៃទៀត។

១១៥. ប្រធាន OAI ត្រូវជូនដំណឹងដល់ស្ថាប័នចូលរួមដទៃទៀត អំពីទោសទណ្ឌនីមួយៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានលក្ខណៈសមស្របទៅតាមកិច្ចព្រមព្រៀងនេះ និងការផ្លាស់ប្តូរនានា ដែលមាន។ ការជូនដំណឹងនេះ ត្រូវដាក់បញ្ចូល (ក) ឈ្មោះ និងព័ត៌មានសម្រាប់ទាក់ទងភាគី ដែលត្រូវបានដាក់ទោសទណ្ឌ (ខ) ការអនុវត្តដែលអាចដាក់ទោសទណ្ឌបាន ដែលបានរកឃើញថា ភាគីបានប្រព្រឹត្ត និង (គ) រយៈពេលនៃការហាមឃាត់ ឬការផ្លាស់ប្តូរនានា។ ស្របជាមួយនឹងកិច្ចព្រមព្រៀងហាមឃាត់ខាងលើ និងជាមួយនឹងនីតិវិធីអំពីការផ្សព្វផ្សាយអំពីការដាក់ទោសទណ្ឌ ការជូនដំណឹង នឹងកម្រិតត្រឹមតែទោសទណ្ឌទាំងឡាយណា ដែលត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីតែប៉ុណ្ណោះ ហើយការជូនដំណឹងនេះ នឹងត្រូវធ្វើតែក្រោយពេលមានការផ្សព្វផ្សាយលើគេហទំព័រនេះតែប៉ុណ្ណោះ។ ការសម្រេចចិត្តនៅពេលក្រោយ ដើម្បីដកទោសទណ្ឌណាមួយចេញពីគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា ប្រសិនបើភាគីដែលមិនអាចទាក់ទងពីដំបូង ប៉ុន្តែ ត្រូវបានរកឃើញនៅពេលក្រោយអាចចាត់ទុកថាជាការផ្លាស់ប្តូរ ដែលនឹងតម្រូវឱ្យមានការដកទោសទណ្ឌនេះចេញពីវិសាលភាពនៃកិច្ចព្រមព្រៀងនេះ បើទោះបីជាទោសទណ្ឌនេះនៅដដែល ប៉ុន្តែមិនត្រូវបានផ្សព្វផ្សាយក៏ដោយ។

១១៦. មានតែភាគីទទួលរងការដាក់ទណ្ឌកម្ម ដែលត្រូវបានកំណត់ដោយស្ថាប័នដាក់ទណ្ឌកម្មតែប៉ុណ្ណោះ ដែលត្រូវទទួលរងការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងហាមឃាត់ឱ្យគ្នាទៅវិញទៅមក។

១១៧. នៅពេលដែលទោសទណ្ឌ ដែលមានលក្ខណៈសមស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តការសម្រេចចិត្តស្តីពីការហាមឃាត់ឱ្យគ្នាទៅវិញទៅមក ត្រូវបានដាក់ដោយស្ថាប័នចូលរួមដទៃទៀត ប្រធាន និងនាយក OAI ត្រូវពិនិត្យលើទោសទណ្ឌ ដើម្បីកំណត់ថាតើ ធនាគារអភិវឌ្ឍន៍អាស៊ី គួរដាក់ទោសទណ្ឌដូចគ្នានេះ ដែរឬទេ។ ប្រសិនបើមានការសម្រេចចិត្តហាមឃាត់ដោយប្រើបញ្ជីឈ្មោះភាគីរបស់ស្ថាប័នផ្សេង ការហាមឃាត់បែបនេះ នឹងត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងជូនដំណឹងដល់អង្គភាពដែលត្រូវបានហាមឃាត់ទៅតាមភាពជាក់ស្តែង។ ដោយសារតែការហាមឃាត់ឱ្យគ្នាទៅវិញទៅមកនេះត្រូវចូលជាធរមានភ្លាមៗ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយលើគេហទំព័រ រយៈពេលនៃការហាមឃាត់ឱ្យគ្នាទៅវិញទៅមកនេះ អាចមានការប្រែប្រួលពីរយៈពេលហាមឃាត់ដំបូង ដែលដាក់ដោយស្ថាប័នចូលរួមក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។ ប្រធាន OAI ត្រូវផ្តល់អនុសាសន៍អំពីការសម្រេចចិត្តមិនហាមឃាត់ក្រុមហ៊ុន ឬ បុគ្គល ដែលមានលក្ខណៈសមស្រប ដើម្បីចូលរួមនៅក្នុងសកម្មភាពទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដល់ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី។

១១៨. នៅពេលដែលការដាក់ទោសទណ្ឌលើភាគី ដែលត្រូវបានហាមឃាត់នេះត្រូវបានដកចេញ ឬ ផ្លាស់ប្តូរដោយស្ថាប័នដែលដាក់ទោសទណ្ឌ នោះការដាក់ទោសទណ្ឌដោយធនាគារអភិវឌ្ឍន៍អាស៊ី ក៏នឹងត្រូវដកចេញ ឬផ្លាស់ប្តូរដូចគ្នាដែរ។

## អំពីធនាគារអភិវឌ្ឍន៍អាស៊ី

ទស្សនវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺតំបន់អាស៊ី និងប៉ាស៊ីហ្វិក គ្មានភាពក្រីក្រ។ បេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិករបស់ខ្លួន កាត់បន្ថយភាពក្រីក្រ និង ធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរស់នៅប្រជាពលរដ្ឋរបស់ពួកគេ។ បើទោះបីជាមានភាពជោគជ័យជាច្រើននៅក្នុងតំបន់ក៏ដោយ ក៏តំបន់នេះ នៅតែមានប្រជាពលរដ្ឋក្រីក្រប្រមាណពីរភាគបីនៃប្រជាពលរដ្ឋក្រីក្រក្នុងពិភពលោក៖ ១,៦ ពាន់លាននាក់ ដែលរស់នៅក្រោមប្រាក់ចំណូលតិចជាង ២ដុល្លាក្នុងមួយថ្ងៃ ក្នុងនោះ ៧៣៣លាននាក់ កំពុងតស៊ូរស់នៅក្រោមប្រាក់ចំណូលតិចជាង ១,២៥ដុល្លា ក្នុងមួយថ្ងៃ។ ធនាគារអភិវឌ្ឍន៍អាស៊ី ប្តេជ្ញាកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា កំណើនសេដ្ឋកិច្ច ដែលធានានិរន្តរភាពបរិស្ថាន និងសមាហរណកម្មតំបន់។

ដោយមានមូលដ្ឋាននៅក្នុងទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស រាប់បញ្ចូលទាំង ៤៨ ប្រទេស នៅក្នុងតំបន់នេះផងដែរ។ យុទ្ធវិធីជាចម្បងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិករបស់ខ្លួន រួមមាន កិច្ចសន្ទនាគោលនយោបាយ ការផ្តល់កម្ចី ការវិនិយោគភាគហ៊ុន ការផ្តល់ការធានា ការផ្តល់ជំនួយឥតសំណង និងជំនួយបច្ចេកទេស។

ADB

**ASIAN DEVELOPMENT BANK**
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
www.adb.org